


សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS


# អំពើទារុណកម្ម និងការធ្វើបាបៈ

## ការផ្តល់ចម្លើយពីខាងក្នុងពន្ធនាគារ និងប៉ុស្តិ៍នគរបាលរបស់កម្ពុជា


របាយការណ៍ចេញ
ខែមិថុនា ឆ្នាំ២០១៤

# អំពើទារុណកម្ម និងការធ្វើបាបៈ

## ការផ្តល់ចម្លើយពីខាងក្នុងពន្ធនាគារ និងប៉ុស្តិ៍នគរបាលរបស់កម្ពុជា

របាយការណ៍ចេញខែមិថុនា ឆ្នាំ២០១៤


សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស  លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅ តាមសាខាទូទាំង ១២ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**

អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

ការហាមឃាត់ដាច់ខាតទៅលើការធ្វើទារុណកម្ម ទំព័រ៣

អំពើហិង្សាលើរាងកាយ និងការគម្រាមកំហែង ទំព័រ៣

ការសារភាពដោយបង្ខំ ទំព័រ៥

ការវាយដំក្នុងពេលចាប់ខ្លួន និងពេលបញ្ជូនខ្លួន ទំព័រ៧

ការបំពានដែលមិនបានរាយការណ៍ ទំព័រ៨

អ្នកជាប់ពន្ធនាគារបំពានលើអ្នកជាប់ពន្ធនាគារ ទំព័រ៩

ការដាក់ទណ្ឌកម្ម ដោយសារការដាក់ពាក្យបណ្តឹង ទំព័រ១០

ការបំពាន និងការផ្សំគំនិតរបស់អាជ្ញាធរពន្ធនាគារ ទំព័រ១១

អំពើហិង្សាលើកុមារមិនត្រូវបានអើពើ ទំព័រ១២

ទារុណកម្ម និងសុខភាពផ្លូវចិត្ត ទំព័រ១៣

វិន័យដែលមិនមានបញ្ញត្តិ ទំព័រ១៥

លក្ខខណ្ឌនៃការឃុំឃាំង ទំព័រ១៧

ការមិនយកចិត្តទុកដាក់ក្នុងការផ្តល់សេវាពេទ្យលើផ្លូវកាយ និងផ្លូវចិត្ត ទំព័រ១៨

កង្វះខាតការដាក់ទោស និងការកែតម្រូវឡើងវិញ ទំព័រ១៩

គណកម្មាធិការអន្តរក្រសួង (មិនឯករាជ្យ និងមិនមានប្រសិទ្ធិភាព) ទំព័រ២០

សេចក្តីបញ្ចប់ ទំព័រ២៣

យោបល់មួយចំនួន ទំព័រ២៤




អ្នកទោសជាបុរសក្នុងពន្ធនាគារកម្ពុជា ឆ្នាំ២០១៣



ប៉ម និងជញ្ជាំងពន្ធនាគារកម្ពុជា ឆ្នាំ២០១០

# សេចក្តីផ្តើម

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើពិធីសារបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប (OPCAT) កាលពីខែមីនា ឆ្នាំ២០០៧។ ក្នុងចំណោមចំណុចឯទៀត ពិធីសារនេះ តម្រូវអោយបណ្តារដ្ឋភាគីទាំងឡាយបង្កើតនូវយន្តការបង្ការថ្នាក់ជាតិ (NPM) ឯករាជ្យមួយក្នុងរយៈពេលមួយឆ្នាំនៃការផ្តល់សច្ចាប័ន។ គោលបំណងចំបងនៃ NPM គឺដើម្បីត្រួតពិនិត្យ និងបង្ការការធ្វើទារុណកម្ម និងការធ្វើបាបនៅក្នុងទីកន្លែងឃុំឃាំង។

ជាងប្រាំពីរឆ្នាំ ក្រោយពីការផ្តល់សច្ចាប័ន អាជ្ញាធរកម្ពុជាមិនទាន់បង្កើតយន្តការនេះនៅឡើយទេ។ ផ្ទុយទៅវិញ គណៈកម្មាធិការអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដែលមានសមាសភាពមកពីមន្ត្រីរាជរដ្ឋាភិបាលផ្សេងៗ។ ស្ថាប័ននេះ គឺមិនមានឯករាជ្យ ហើយក៏មិនមានសមត្ថភាពដើម្បីអនុវត្តមុខងាររបស់យន្តការបង្ការថ្នាក់ជាតិ (NPM) ដែលមានប្រសិទ្ធភាពមួយ។លើសពីនេះ ចាប់តាំងពីការបង្កើតរបស់ខ្លួនក្នុងឆ្នាំ២០០៩ គណៈកម្មាធិការនេះបានបំពេញការងារតិចតួចណាស់នៃមុខងារជាក់ស្តែង។

គួរអោយសោកស្តាយ មិនមានការបង្ហាញណាមួយ ដែលបញ្ជាក់ថាគណៈកម្មាធិការនេះ នឹងត្រូវផ្លាស់ប្តូរដោយយន្តការបង្ការថ្នាក់ជាតិ (NPM) មួយដែលឯករាជ្យពិត ប្រាកដ និងអាចដំណើរការក្នុងអនាគតដ៏ខ្លីនោះទេ។ មិនតែប៉ុណ្ណោះ នៅក្នុងសន្និសីទ ខែធ្នូ ឆ្នាំ២០១៣[១] ដែលត្រូវបានរៀបចំឡើង ដើម្បីបង្ហាញនូវការមកដល់ប្រទេសកម្ពុជា នៃអនុគណៈកម្មាធិការរបស់អង្គការសហប្រជាជាតិស្តីពីបង្ការអំពើទារុណកម្ម (SPT) ដែលជាស្ថាប័នត្រួតពិនិត្យអន្តរជាតិមួយបង្កើតឡើងនៅក្រោមពិធីសារ OPCAT អាជ្ញាធរកម្ពុជា បានបង្ហាញការបន្តប្រឆាំងរបស់អ្នកទាំងនោះ ហើយចំពោះករណីខ្លះ ពួកគេបានបង្ហាញអរិភាពដាច់ខាតរបស់ពួកគេ ចំពោះការបង្កើតឡើងនូវយន្តការបង្ការថ្នាក់ជាតិ (NPM)។

នៅចំពោះមុខការមិនអនុវត្តកាតព្វកិច្ចអន្តរជាតិបែបនេះ មិនមានអ្វីគួរអោយភ្ញាក់ផ្អើលនោះទេ ដែលកម្រិតនៃការធ្វើទារុណកម្ម និងការធ្វើបាបក្នុងប្រទេសកម្ពុជា នៅតែមានកម្រិតខ្ពស់មធ្យោបាយសម្រាប់ដាក់ពាក្យបណ្តឹងមានកំណត់ និងអ្នកដែលប្រព្រឹត្តអំពើហិង្សាទាំងនោះកម្រនឹងទទួលរងការដាក់ទណ្ឌកម្ម។

ចាប់តាំងពីខែ មករា ឆ្នាំ២០០៨ អង្គការ លីកាដូ បានទទួលជាង៥០០ករណី នៃការអះអាងយ៉ាងលំអិត អំពីការធ្វើទារុណកម្ម ឬការធ្វើបាប បង្កដោយមន្ត្រីនៅក្នុងប៉ុស្តិ៍នគរបាល និងពន្ធនាគារកម្ពុជា ដែលក្នុងនោះរួមមានការប្រើអំពើហិង្សាលើអ្នកទោសជាស្ត្រី និងអនីតិជន ហើយនឹងអ្នកដែលធ្លាប់មានបញ្ហាផ្លូវចិត្ត។ អង្គការ លីកាដូ

[១] សិក្ខាសាលាពិគ្រោះយោបល់ជាន់ខ្ពស់អំពីយន្តការបង្ការជាតិឯករាជ្យនៅក្នុងប្រទេសកម្ពុជា(១៦-១៧ ខែធ្នូ ឆ្នាំ២០១៣), ធ្វើឡើងនៅសណ្ឋាគារអ៊ិនធឺកង់ទីណង់តាល់ ក្រុងភ្នំពេញ

មានការព្រួយបារម្ភថាអត្រាជាក់ស្តែង នៃការបំពានអាចមានចំនួនច្រើនជាងនេះ។

លើសពីនេះ អង្គការ លីកាដូ តែងតែកត់ត្រាទុកជាទៀងទាត់ អំពើហិង្សាប្រព្រឹត្តដោយនគរបាល និងកងកម្លាំងសន្តិសុខដទៃទៀត នៅពេលចាប់ខ្លួន និងនៅក្នុងពេលការបញ្ជូនទៅប៉ុស្តិ៍នគរបាល។ នៅពេលចូលទៅក្នុងពន្ធនាគារ អ្នកជាប់ពន្ធនាគារមិនត្រឹមតែទទួលរងការបំពានពីឆ្មាំពន្ធនាគារប៉ុណ្ណោះទេ អ្នកទាំងនោះក៏ទទួលរងការបំពានពីអ្នកជាប់ពន្ធនាគារឯទៀត ដែលជាញឹកញាប់នៅក្រោមការបញ្ជាដោយផ្ទាល់ ឬដោយការយល់ព្រមពីអាជ្ញាធរពន្ធនាគារ។

បន្ថែមពីនេះទៀត អង្គការ លីកាដូ ជឿជាក់ថាស្ថានភាពឃុំឃាំងនៅកន្លែងឃុំឃាំងខ្លះ អាចកើតមានឡើងនូវអំពើឃោរឃៅឥតមនុស្សធម៌ ឬបន្ថោកបន្ទាប និងរួមមានការបដិសេធមិនផ្តល់ការព្យាបាលសមរម្យផងដែរ។

អង្គការ លីកាដូ បានកំពុងធ្វើការនៅក្នុងពន្ធនាគារកម្ពុជាជាង២០ឆ្នាំ ដើម្បីលើកស្ទួយ និងការពារសិទ្ធរបស់អ្នកជាប់ពន្ធនាគារ។ ចាប់តាំងពីឆ្នាំ១៩៩៣ អង្គការ លីកាដូ បានកំពុងធ្វើការ ត្រួតពិនិត្យស្ថានភាពពន្ធនាគារកំពុងប្រមូល និងវិភាគទិន្នន័យ ហើយនឹងកំពុងធ្វើការទាក់ទាញមតិគាំទ្រក្នុងនាមជាអ្នកជាប់ពន្ធនាគារ។ អង្គការ លីកាដូ ក៏មានការផ្តល់ការតំណាង និងសេវាផ្នែកច្បាប់ ការព្យាបាល និងជំនួយចាំបាច់ផ្សេងទៀតទៅអោយអ្នកជាប់ពន្ធនាគារ ហើយនៅក្នុងករណីខ្លះ ក៏ផ្តល់ទៅអោយគ្រួសាររបស់អ្នកទាំងនោះផងដែរ។

យន្តការត្រួតពិនិត្យចំបងរបស់អង្គការ លីកាដូ គឺការជួបសម្ភាសន៍ជាពៀងរាល់សប្តាហ៍ជាមួយនឹងអ្នកជាប់ពន្ធនាគារបណ្តោះអាសន្នរង់ចាំសវនាការ និងទណ្ឌិត និងសមាជិកគ្រួសាររបស់អ្នកជាប់ពន្ធនាគារ និងរបស់អ្នកជាប់ពន្ធនាគារដែលត្រូវបានដោះលែង។ តាមរយៈបទសម្ភាសន៍ទាំងនេះ អង្គការ លីកាដូ អាចត្រួតពិនិត្យទៅលើស្ថានភាពពន្ធនាគារអាចរកឃើញអ្នកជាប់ពន្ធនាគារ ដែលមានតម្រូវការផ្នែកច្បាប់ និងការព្យាបាល ហើយនិងអាចលាតត្រដាងអោយឃើញព្រឹត្តការណ៍នៃការធ្វើទារុណកម្ម។

អង្គការ លីកាដូ តែងតែត្រួតពិនិត្យទៅលើពន្ធនាគារចំនួន ១៨ កន្លែងក្នុងចំណោមពន្ធនាគារទាំង ២៨កន្លែង នៅប្រទេសកម្ពុជាជាទៀងទាត់។[២] រាជរដ្ឋាភិបាលមិនអនុញ្ញាតអោយអង្គការមិនមែនរដ្ឋាភិបាលត្រួតពិនិត្យជាទៀងទាត់ ទៅលើកន្លែងឃុំឃាំងរបស់នគរបាល ដូច្នេះអង្គការ លីកាដូ ពឹងផ្អែកទៅលើការជួបសម្ភាសន៍ជាមួយអ្នកជាប់ពន្ធនាគារបច្ចុប្បន្ន និងអតីតអ្នកជាប់ពន្ធនាគារ ដើម្បីស្វែងយល់ពីស្ថានភាពនៃការឃុំឃាំង និងឥរិយាបថចំពោះអ្នកជាប់ឃុំឃាំងនៅប៉ុស្តិ៍នគរបាល។

ចាប់តាំងពីឆ្នាំ២០០៨ អ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការ លីកាដូ បានសម្ភាសន៍អ្នកដែលជាប់ឃុំឃាំង ឬអ្នកដែលទើបតែត្រូវបានដោះលែងជាង ១១,០០០នាក់។ ក្នុងចំណោមនោះ ជាង ៥០០ នាក់បានរាយការណ៍ថាអ្នកទាំងនោះ បានទទួលរងការធ្វើទារុណកម្ម ឬការធ្វើបាប ពេលនៅក្នុងពន្ធនាគារ ឬពេលនៅក្នុងការឃុំរបស់នគរបាល។ ស្ថិតិរបស់អង្គការ លីកាដូ បង្ហាញថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ មានការផ្លាស់ប្តូរតិចតួចណាស់ចំពោះ ទំហំនៃអ្នកដែលបានរាយការណ៍អំពើហិង្សា។

អង្គការ លីកាដូ មិនបានត្រួតពិនិត្យទៀងទាត់ទៅលើកន្លែងឯដទៃទៀត ដែលសេរីភាពរបស់ប្រជាពលរដ្ឋត្រូវបានដកហូត ដែលមានដូចជា មណ្ឌលសង្គមកិច្ច និងស្ថានីតិសម្បទាគ្រឿងញៀននោះឡើយ។[៣]

### ចំនួនអ្នកទោស និងអត្រាមធ្យមនៃចំនួនអ្នកទោស ឃ្លាំមើលដោយអង្គការ លីកាដូ




[២] ពន្ធនាគារនៅស្នងការរាជធានីភ្នំពេញ (PJ) ម១ ម២ ម៣ ម៤ តាខ្មៅ ព្រះសីហនុ កំពង់ស្ពឺ កំពត កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ស្វាយរៀង និងកោះកុង។

[៣] សម្រាប់ពត៌មានបន្ថែមអំពីរបាយការណ៍នៃការបំពានសិទ្ធិមនុស្សនៅក្នុងមន្ទីរឃុំឃាំងសង្គមកិច្ច និង គ្រឿងញៀន សូមមើលរបាយការណ៍ឃ្លាំមើលសិទ្ធមនុស្ស៖ “ពួកគេចាត់ទុកយើងដូចជាសត្វធាតុ៖ ការធ្វើបាបទៅអ្នកប្រើប្រាស់គ្រឿងញៀន និង “Undesirables” នៅក្នុងមន្ទីរឃុំឃាំងគ្រឿងញៀនក្នុងប្រទេសកម្ពុជា៖ http://www.hrw.org/node/120957

# ការហាមឃាត់ដាច់ខាតនៅលើការធ្វើទារុណកម្ម

ការធ្វើទារុណកម្ម ត្រូវបានហាមខាត់ដាច់ខាតនៅក្រោមច្បាប់អន្តរជាតិ ហើយវាមិនអាចលើកលែងឲ្យបានទោះបីនៅក្នុងករណីណាក៏ដោយ។ រដ្ឋត្រូវតែធានាអោយមានការស៊ើបអង្កេតឆាប់រហ័សមួយទៅលើការធ្វើទារុណកម្មដែលបានអះអាង ហើយដាក់ទោសអ្នកប្រព្រឹត្តិ និងផ្តល់សិទ្ធដល់ជនរងគ្រោះក្នុងការទទួលបានសំណង។ រដ្ឋក៏មានកាតព្វកិច្ចក្នុងការប្រើប្រាស់ស្ថាប័ននិតិបញ្ញត្តិ រដ្ឋបាល តុលាការ និងវិធានការផ្សេងទៀត ដែលមានប្រសិទ្ធភាពដើម្បីទប់ស្កាត់ការធ្វើអំពើទារុណកម្ម ឬការធ្វើបាប នៅក្នុងតំបន់ណាដែលនៅក្រោមដែនសមត្ថកិច្ចរបស់អ្នកទាំងនោះ។

យោងតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (OPCAT) ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅក្នុងឆ្នាំ១៩៩២ ការធ្វើទារុណកម្មអាចកំណត់ន័យថា ជាអំពើដោយចេតនា ដែលធ្វើអោយមានការឈឺចាប់ ឬការរង ទុក្ខវេទនាធ្ងន់ធ្ងរផ្នែកស្មារតី ឬរាងកាយ ដោយសារ ឬជាមួយនឹងការអនុញ្ញាត ឬ ការយល់ព្រមនៃអាជ្ញាធររដ្ឋ ដែលធ្វើឡើងសម្រាប់គោល បំណងជាក់លាក់ដូចជាដើម្បីទទួលបានពត៌មាន ការដាក់ទណ្ឌកម្ម ឬ ការបំភ័យ។

អំពើ ឬ ការដាក់ទណ្ឌកម្ម ឃោរឃៅ ឥតមនុស្សធម៌ ឬបន្ថោកបន្ទាប[៤] ត្រូវបានហាមឃាត់ក្រោមច្បាប់អន្តរជាតិ។ ខណៈដែលគ្មាននិយមន័យសម្រាប់អំពើឃោរឃៅ ឥតមនុស្សធម៌ ឬបន្ថោកបន្ទាបក្រោមច្បាប់អន្តរជាតិ អំពើ ឬការដាក់ទណ្ឌកម្ម អាចចាត់ទុកថាជាអំពើឃោរឃៅ ឥតមនុស្សធម៌ ឬបន្ថោកបន្ទាប បើសិនវាមានភាពមិនសមរម្យ មិនចាំបាច់ តាមតែអំពើចិត្ត ឬមិនសមហេតុផល ហើយបើសិនវាបង្កអោយមានការឈឺចាប់ និង/ឬទុក្ខលំបាកវេទនា ប៉ុន្តែវាមិនរួមមានធាតុទាំងអស់នៃនិយមន័យនៃការធ្វើទារុណកម្ម។

ច្បាប់កម្ពុជា ហាមឃាត់ការធ្វើទារុណកម្ម ប៉ុន្តែវាមិនរួមបញ្ចូលនិយមន័យនៃពាក្យនោះទេ។ ការខ្វះខាតនៃពាក្យបច្ចេកទេសច្បាស់លាស់បែបនេះ គឺជាឧបសគ្គធំមួយ ក្នុងការបង្កើនការស្វែងយល់អំពីអ្វីទៅដែលបង្កើតអោយមានការធ្វើទារុណកម្ម និងការទប់ស្កាត់នោះនៅក្នុងតុលាការ និងក្នុងចំណោមមន្ត្រីដែលប្រតិបត្តិច្បាប់។

ករណីជាច្រើននៃអំពើហិង្សា និងការទណ្ឌកម្មនៅក្នុងការឃុំឃាំងរបស់នគរបាល និងនៅក្នុងពន្ធនាគារ ដែលអង្គការ លីកាដូ ទទួលបាន គឺបង្កឡើងដោយអំពើទារុណកម្ម។ ករណីខ្លះ គឺបង្កដោយការបំពាន ដោយសារមន្ត្រីរដ្ឋាភិបាល ហើយករណីឯទៀត គឺបង្កដោយការបំពានពីអ្នកជាប់ពន្ធនាគារផ្សេងទៀត ដោយនៅក្រោមការបញ្ជាដោយផ្ទាល់ ឬជាមួយការដឹងលឺពីមន្ត្រី ដែលបន្ទាប់មកមិនបានធ្វើសកម្មភាពដើម្បីទប់ស្កាត់ការបំពាន។ អជ្ញាធរជាទៀតទាត់មិនបានស៊ើបអង្កេតរបាយការណ៍អំពីអំពើហិង្សា ដាក់ទោសជនល្មើស ឬធានាអោយជនរងគ្រោះនឹងទទួលបានសំណងនោះឡើយ។

> “ពួកគេវាយខ្លួនខ្ញុំគ្រប់កន្លែង ព្រមទាំងក្បាល មុខ និងទ្រូងខ្ញុំ... ពួកគេប្រើអគ្គីសនីមកឆក់ខ្ញុំ។ ក្បាលខ្ញុំត្រូវបានគេវាយដោយប្រើកណ្តាប់ដៃ និងដំបង... មុខខ្ញុំត្រូវបានជាន់សង្កត់ទៅនឹងដី។ ពួកគេទាត់ខ្ញុំត្រង់ឆ្អឹងជំនីរបស់ខ្ញុំជាមួយនឹងស្បែកជើងប៊ូតរបស់ពួកគេ ។ ខ្ញុំឈឺខ្លាំងណាស់ ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំជិតស្លាប់ទៅហើយ។”
>
> បុរសម្នាក់ ដែលបានរាយការណ៍អំពីការបំពាននៅប៉ុស្តិ៍នគរបាលខេត្ត កាលពីឆ្នាំ២០១៣

# អំពើហិង្សាលើរាងកាយ និងការគំរាមកំហែង

ទិន្នន័យរបស់អង្គការ លីកាដូ បង្ហាញអោយឃើញថា មនុស្សភាគច្រើន ដែលបានរាយការណ៍អំពីអំពើព្រៃផ្សៃដោយនគរបាល ឬមន្ត្រីពន្ធនាគារ តាំងពីឆ្នាំ២០០៨ បានរៀបរាប់ថា អ្នកទាំងនោះត្រូវបានវាយ ទាត់ ទះ ឬដាល់ ដែលជាញឹកញាប់រហូតដល់ពួកគាត់ហូរឈាម ហើយបាត់បង់ស្មារតី ។ មនុស្សជាច្រើនត្រូវបានវាយគ្រប់កន្លែងលើខ្លួនរបស់ពួកគាត់ ព្រមទាំងក្បាល និងក។ អ្នកខ្លះត្រូវបានគេយកក្បាលរបស់គាត់ទៅជល់ជាមួយនិងជញ្ជាំង។

វត្ថុប្រើប្រាស់ពេលវាយដំ រួមមាន កាំភ្លើង ដំបង ដំបង(រំពាត់)ដែក ដំបងឆក វិទ្យុទាក់ទង(អាយគូម) ខ្នោះដៃ ច្រវាក់ដែក ខ្សែពួរ ខ្សែភ្លើងអគ្គីសនី ឥដ្ឋ និងខ្សែក្រវាត់។ អ្នកជាប់ឃុំឃាំងខ្លះ ត្រូវបានគេគ្របមុខជាមួយថង់ប្លាស្ទិក ឬវត្ថុផ្សេងទៀត ក្នុងកំឡុងពេលវាយដំ។ មនុស្សជាច្រើន ដែលត្រូវបានសម្ភាសន៍បាននិយាយថា ពួកគាត់ត្រូវបានគេវាយ ដើម្បីបង្ខំអោយពួកគាត់សារភាព ឬបង់ប្រាក់ទៅអោយអ្នកដែលបំពានពួកគាត់។ អ្នកដែលមិនចេះអានអក្សរខ្មែរត្រូវបានគេបង្ខំអោយផ្តិតមេដៃលើលិខិតសារភាព ដែលអ្នកទាំងនោះមិនយល់។

អង្គការ លីកាដូ ក៏បានទទួលរបាយការណ៍អំពីអ្នកជាប់ពន្ធនាគារ ដែលត្រូវបានគេអូសលើដីដោយចាប់ទាញសក់របស់ពួកគាត់ របាយការណ៍អំពីអ្នកជាប់ពន្ធនាគារ ដែលត្រូវបានបង្ខំអោយឈរជើងមួយរយៈពេលយូរ របាយការណ៍អំពីអ្នកយាមឈរហើយជាន់លើដងខ្លួន និងមុខរបស់អ្នកទាំងនោះរបាយការណ៍អំពីវត្ថុដែលត្រូវបានគេបង្ខំញាត់ចូលទៅក្នុងមាត់អ្នកទាំងនោះ របាយការណ៍ការពីការរលាកបារី របាយការណ៍អំពីការបង្ខំអោយអ្នកជាប់ពន្ធនាគារលត់ជង្គង់រយៈពេលយូរព្រមទាំងនៅក្រោមកំដៅថ្ងៃ របាយការណ៍អំពីការច្របាច់ក និងការប្រើប្រាស់អគ្គីសនីឆក់សម្រាប់ធ្វើទារុណកម្ម។

[៤]សម្រាប់គោលបំណងនៃឯកសារ អំពើ ឬការដាក់ទណ្ឌកម្ម ឃោរឃៅ ឥតមនុស្សធម៌ ឬបន្ថោកបន្ទាប គឺពេលខ្លះសំដៅចំពោះការធ្វើបាប ឬការបំពាន។

មនុស្សជាច្រើនបានរាយការណ៍ថា ពួកគាត់ត្រូវបានគេគម្រាម ឬ គ្រួសាររបស់ពួកគាត់ ត្រូវបានគេគម្រាម ដោយនគរបាល ឬ អាជ្ញាធរពន្ធនាគារ ដែលជាធម្មតា ដើម្បីទារប្រាក់ ឬការឆ្លើយសារភាព។ អ្នកខ្លះ ត្រូវបានគម្រាមសម្លាប់ ឬបំពានផ្លូវភេទ ហើយអ្នកឯទៀតត្រូវបានគេភ្ជង់កាំ ភ្លើងដាក់ក្បាលរបស់ពួកគាត់ ឬត្រូវបានគម្រាមជាមួយនឹងការឆក់អគ្គីសនី។ ការគម្រាមដក ក្រចកដៃ ក៏ត្រូវបានរាយការណ៍ផងដែរ។ អ្នកជាច្រើនបាននិយាយថា ពួកគាត់ត្រូវបានគេបង្អត់អាហារ និងទឹកនៅក្នុងការឃុំឃាំងរបស់នគរបាល។

អង្គការ លីកាដូ បានវិភាគអំពីខ្លឹមសារនៃសក្ខីភាព ដែលបានទទួល ពីចន្លោះខែមករា ឆ្នាំ២០០៨ និងខែមិថុនា ឆ្នាំ២០១៤ ហើយលីកាដូ បានរកឃើញថា មិនមានការផ្លាស់ប្តូរដែលអាច មើលឃើញណាមួយ ចំពោះប្រភេទភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃការបំពានដែលបានរាយការណ៍នៅក្នុងកំឡុងពេលនោះឡើយ។

នៅក្នុងបួនខែដំបូងនៃឆ្នាំ២០១៤ តែប៉ុណ្ណោះ អង្គការ លីកាដូ បានទទួលលិខិតចោទប្រកាន់ចំនួន ៤៩ករណី អំពីការធ្វើទារុណកម្ម ឬ ការធ្វើបាប ក្នុងអំឡុងពេលចាប់ខ្លួន ឬ នៅក្នុងការឃុំឃាំងរបស់នគរបាល។ នៅក្នុងឆ្នាំ២០១៤ អ្នកជាប់ឃុំឃាំងត្រូវបានគេទះ ទាត់ត្រង់ឆ្អឹងជំនី និងដើមទ្រូង ហើយពួកគាត់ត្រូវបានគេវាយចំក្បាល និងដងខ្លួនជាមួយនឹងដំបង និងដំបងឆក់។ ភ្នាក់ងារនគរបាលបានជាន់លើដៃអ្នកទោស ហើយក្នុងករណីមួយ អ្នកទាំងនោះ បានគ្របក្បាលបុរសម្នាក់ជាមួយនឹងថង់ប្លាស្ទិក ខណៈដែលគាត់កំពុងដេកនៅលើឥដ្ឋ ហើយពួកគេបានជាន់ លើខ្លួនរបស់គាត់ ហើយទាត់គាត់ត្រង់ឆ្អឹងជំនីជាច្រើនសារ។

ចំណុចមួយក្នុងចំណោមគោលបំណងចំបងៗនៃការបំពាន គឺនៅតែបន្តជាការបង្ខំដើម្បីទាមទារការសារភាព ឬប្រាក់កាស។

នៅក្នុងពីទៅបីខែដំបូងនៃឆ្នាំ២០១៤ ក៏ដូចជានៅក្នុងឆ្នាំពីមុនៗផងដែរ បណ្តឹងខ្លះអំពី ការបំពាន គឺទទួលបានមកពីអ្នកទោសស្រី។ ស្ត្រីម្នាក់ត្រូវបានគេទាត់ត្រង់ឆ្អឹងជំនីរហូតដល់គាត់បានប ង់ស្មារតី ចំណែកឯស្ត្រីម្នាក់ទៀតត្រូវបានគេទះ ទាត់ និងវាយជាមួយនឹងដំបងជំរជាច្រើន លើករហូតដល់គាត់បាត់បង់ស្មារតី ហើយស្ត្រីទីបី ដែលនៅពេលនោះកំពុងមានផ្ទៃពោះពីរខែត្រូវ បានគេគម្រាមសម្លាប់។



ច្រកចូលប៉ុស្តិ៍នគរបាលរាជធានីភ្នំពេញ ឆ្នាំ២០១៤

## វាយរហូតដល់បាត់បង់ស្មារតី

រ័ត្ន (មិនឈ្មោះពិតរបស់គាត់) ត្រូវបានចាប់ខ្លួននៅខែ មករា ឆ្នាំ២០១៣។ គាត់ត្រូវបានគេយកទៅទីស្នាក់ការនគរបាលមូលដ្ឋាន ដែលទីនោះ គាត់ត្រូវបានវាយដោយនគរបាលប្រាំមួយនាក់រហូតដល់គាត់បាត់បង់ស្មារតី។ ដោយដៃរបស់គាត់ត្រូវបានជាប់ ខ្នោះនៅខាងក្រោយខ្នងពួកគេទាត់ និងដាល់គាត់នៅចំពោះ និងវាយគាត់អោយ បាក់ធ្មេញ។ ក្រោយមកអ្នកទាំងនោះ បានជាន់ពីលើដើមទ្រូង និងខ្នងរបស់គាត់នៅ ពេលដែលគាត់សម្រានលើដី។ ពេលគាត់ ព្យាយាមទទួលទានដំណេក អ្នកទាំងនោះបានទះមុខរបស់គាត់។ ក្រោយមក គាត់បានសារភាពចំពោះបទឧក្រិដ្ឋកម្មដែលគេបានអះអាង។

> “នគរបាលស្រីបានឆែកខ្លួនរបស់ខ្ញុំ ហើយសួរថា ខ្ញុំបានទិញគ្រឿងញៀនហ្នឹងមកពីណា។ គាត់និយាយថា បើសិនជាខ្ញុំមិនឆ្លើយ គាត់នឹងវាយខ្ញុំរហូតដល់ស្លាប់... ខ្ញុំពិតជាខ្លាចខ្លាំងណាស់។ នគរបាលប្រុសជាន់លើខ្នោះដៃនៅខាងក្រោមខ្នងខ្ញុំធ្វើអោយខ្ញុំដួលទៅក្រោយ... ខ្ញុំភ័យខ្លាចថា ខ្ញុំនឹងរលូតកូន។”

ស្ត្រីម្នាក់ ដែលរាយការណ៍ពីការបំពាននៅទីស្នាក់ការនគរបាលភ្នំពេញ កាលពីឆ្នាំ២០១៤

# ការសារភាពដោយបង្ខំ

តាំងពីឆ្នាំ២០០៨ ៩០ភាគរយ នៃបទបំពានដែលបានរាយការណ៍មកកាន់អង្គការ លីកាដូ គឺត្រូវបានអះអាងថា វាកើតឡើងនៅក្នុងការឃុំឃាំងរបស់នគរបាល ដែលជាញឹកញាប់នៃការបំពានគឺនៅក្នុងទម្រង់នៃការទាញយកការសារភាព។

អំពើប្រព្រឹត្តទៅលើអ្នកសង្ស័យនៅទីស្នាក់ការនគរបាលក្នុងប្រទេសកម្ពុជា គឺគួរអោយព្រួយបារម្ភពីព្រោះច្បាប់មិនបានអនុញ្ញាតជនសង្ស័យ អោយនិយាយជាមួយមេធាវី ឬសមាជិក គ្រួសារ ក្នុងអំឡុងពេល២៤ ម៉ោងដំបូង នៃការឃុំឃាំង ហើយអ្នកជាប់ឃុំឃាំកម្រនឹងទទួលបានការផ្តល់ព័ត៌មានអំពីសិទ្ធរបស់អ្នកទាំងនោះ នៅពេលដែលត្រូវបានចាប់ខ្លួន។ យោងតាមមាត្រា៩៨ នៃក្រមនិតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ទាល់តែ "បន្ទាប់ពី រយៈពេល ២៤ម៉ោង ចាប់តាំងពីការចាប់ផ្តើមឃុំខ្លួនរបស់នគរបាលបានផុតទើបអ្នក ជាប់ឃុំឃាំងអាចស្នើសុំ ជួបនិយាយជាមួយមេធាវី ឬអ្នកឯទៀត..."។ បន្ថែមពីនេះទៀត ច្បាប់ទាក់ទងនឹងការឃុំខ្លួនអនីតិជន ក៏មិនបានបញ្ជាក់ពីរយៈពេលជាក់លាក់សម្រាប ជូនដំណឹងទៅដល់មាតាបិតា ឬ អាណាព្យាបាល បន្ទាប់ពីការចាប់ខ្លួននោះឡើយ។

ក្រោមច្បាប់នេះ ជនសង្ស័យអាចត្រូវបានឃុំឃាំង ដោយគ្មានមធ្យោបាយទាក់ទង[៥] រយៈពេលយ៉ាងតិច ២៤ម៉ោង ហើយអ្នកទាំងនោះជាធម្មតាត្រូវបានសួរចំលើយដោយមិនមានវត្តមាននៃអ្នកតំណាងផ្នែកច្បាប់ ដោយពួកគាត់មិនបានទទួលព័ត៌មានអំពីសិទ្ធរបស់គាត់ក្នុងការរកមេធាវី ឬសិទ្ធរបស់គាត់ក្នុងការមិនឆ្លើយសំនួរនគរបាលឡើយ។ នៅក្នុងកំឡុងពេលដំបូងនេះ ហើយដែលការសារភាពត្រូវបានទាញយកបាន ដែលជាញឹកញាប់នៅក្រោម ឬក្នុងការបង្ខិតបង្ខំ។

នគរបាលភាគច្រើនខ្វះខាតការហ្វឹកហ្វឺន ធនធាន និងការផ្តល់គ្រឿងលើកទឹកចិត្តចាំបាច់ ដើម្បីធ្វើប្រតិបត្តិការស៊ើបអង្កេតដែលមិនលំអៀង និងមានមូលដ្ឋាន លើការពិត ហើយដូច្នេះការយកចិត្តទុកដាក់ចំបងរបស់ពួកគេគឺទាញយកការសារភាពដ៏លឿនមួយ ដែលជាញឹកញាក់ដោយសារ ប្រើប្រាស់វិធីស្រាស្តខុសច្បាប់។ ការសារភាពបែបនេះកម្រទទួលបានការកោះហៅចូលទៅសាក សួរនៅក្នុងចំណាត់ការតុលាការ ហើយជាញឹកញាប់ការសារភាពនេះ ត្រូវបានយកទៅប្រើប្រាស់ជាគោលជំហរតែមួយគត់ក្នុងការកាត់ក្តី។

ការរីកដុះដាលនៃអំពើពុករលួយនៅក្នុងសេវានគរបាល បានបន្តអោយមានការបំពាន។ ការសន្និដ្ឋាននៃការសង្កេតការណ៍របស់គណៈកម្មាធិការប្រឆាំងទារុណកម្មអង្គសហប្រជាជាតិ នៅក្នុងរបាយការណ៍កម្ពុជាលើកទី២ ក្នុងឆ្នាំ២០១០ បានកត់សំគាល់ថាមុខងារនៃនគរបាល គឺទទួល រងឥទ្ធិពលលើសលុបពីអន្តរាគមន៍នយោបាយ និងអំពើពុករលួយ។ អង្គការ លីកាដូ មិនជឿថាមានការរីកចំរើនណាមួយទេ ចំពោះបញ្ហានេះ តាំងពីឆ្នាំ២០១០។

"...គណៈកម្មាធិការ បានបង្ហាញការព្រួយបារម្ភរបស់ខ្លួនចំពោះរបាយការណ៍ ដែលភ្នាក់ងារនគរបាលបានឡើងឋានន្តរស័ក្តិសម្រាប់ការកាត់ទោស និងរបាយការណ៍ ដែលទីស្នាក់ការនគរបាលបានទទួលគ្រឿងលើកទឹកចិត្តពិសេសសម្រាប់ការកាត់ទោស ដែលបង្កើតអោយមានប្រព័ន្ធផ្តល់រង្វាន់មួយ ហើយក៏ដូចជារបាយការណ៍អំពីភ្នាក់ងារនគរបាលទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុពីការរៀបចំក្រៅផ្លូវការ ឬការដោះស្រាយក្រៅអំណាចតុលាការ។"[៦]

អង្គកា លីកាដូ មិនមានការជឿជាក់ ថាមានភាពប្រសើរឡើងអំពីបញ្ហានេះ

## បង្ខំអោយសារភាពចម្លើយ

"នៅពេលដែលនគរបាលសួរខ្ញុំ គាត់ប្រើអគ្គីសនីឆក់រហូតដល់ខ្ញុំសន្លប់។ គាត់ក៏វាយខ្ញុំចំកញ្ចឹងកជាមួយនឹងម៉ាឡេត ដើម្បីបង្ខំខ្ញុំអោយព្រមទទួលថាខ្ញុំបានលួចម៉ូតូ។ បន្ទាប់ពីខ្ញុំត្រូវបានគេវាយជាច្រើនដង ខ្ញុំបានសារភាពទោះបីជាខ្ញុំមិនបានធ្វើក៏ដោយ។"
បុរសម្នាក់រាយការណ៍ពីការបំពាននៅទីស្នាក់ការនគរបាលខេត្ត កាលពីឆ្នាំ២០១២។

"នៅទីស្នាក់ការនគរបាលមាននគរបាល ជាច្រើននាក់បានដាល់ និងទាត់ខ្ញុំយ៉ាង ឃោរឃៅ។ អ្នកទាំងនោះក៏វាយខ្ញុំជាមួយ និងដំបងឈើ និងវិទ្យុទាក់ទងផងដែរ។ ពួកគេឆក់ខ្ញុំជាមួយនឹងដំបងឆក់ ដើម្បីបង្ខំខ្ញុំអោយសារភាព ចំពោះអំពើប្លន់ជា ច្រើនខុសៗគ្នា។ នៅពេលដែលខ្ញុំបន្តបដិសេធ ពួកគេបន្តវាយខ្ញុំ និងធ្វើទារុណកម្មខ្ញុំ រយៈពេលច្រើនម៉ោង។ អ្នកទាំងនោះបានឈប់ ទាល់តែនៅពេលខ្ញុំដាច់ចិត្ត ប្រាប់ពួកគេថា 'អ្នកមិនចាំបាច់បង្ខំខ្ញុំទេ។ អ្នកអាចសរសេរអ្វី ដែលអ្នកចង់សរសេរក្នុងលិខិតសារភាព។ ខ្ញុំនឹងអោយស្នាមមេដៃខ្ញុំទៅអ្នក'។ ខ្ញុំផ្តិតស្នាមមេដៃខ្ញុំលើលិខិតសារភាព ដែលបានសរសេររួចហើយ"។

"...ពួកគេដាល់ ទះ និងទាត់ខ្ញុំយ៉ាង ឃោរឃៅ... ហើយវាយខ្ញុំជាមួយនឹងដំបង. . . ខ្លួនខ្ញុំគ្មានកំលាំងទាល់សោះ ហើយខ្ញុំសន្លប់ច្រើនដងណាស់។ ពួកគេធ្វើទារុណកម្មខ្ញុំ ៤ ឬ ៥ថ្ងៃ...ទាំងពេល ព្រឹក និងពេលយប់។ អ្នកដែលធ្វើទារុណកម្មខ្ញុំ ជាអ្នកដែលមានសមត្ថកិច្ចនៅនឹងកន្លែង ដែលអំពើប្លន់កើតមានឡើង។ ខ្ញុំមិនអាចទ្រាំនឹងទារុណកម្មបាន ។ ខ្ញុំបានសារភាព ដើម្បីអោយអ្នកទាំងនោះឈប់ធ្វើទារុណកម្មមកលើខ្ញុំ។" បុរសម្នាក់ ដែលបានរាយការណ៍អំពីការបំពាននៅប៉ុស្តិ៍នគរបាលខេត្ត កាលពីឆ្នាំ២០១៣។

[៥] យោងតាម អង្គការលើកលែងទោសអន្តរជាតិ ការឃុំឃាត់ដោយគ្មានមធ្យោបាយទាក់ទងជំរុណអោយមានការធ្វើទារុណកម្ម និងនាំអោយមាន អំពើ ឬការដាក់ទណ្ឌកម្ម ឬការធ្វើទារុណកម្ម ឃោរឃៅ ឥតមនុស្សធម៌ ឬបន្ថោកបន្ទាប។ សូមមើល Torture in 2014: 30 Years of Broken Promises, p.12 http://www.amnesty.org/en/library/asset/ACT40/004/2014/en/96fde57f-61d9-487b-90dc-7da21c6c505d/act400042014en.pdf

[៦] គណៈកម្មាធិការប្រឆាំងទារុណកម្ម, ការប្រជុំលើកទីសែសិបប្រាំ, ថ្ងៃទី១-១៩ ខែវិច្ឆិកា ឆ្នាំ២០១០. សន្និដ្ឋានការសង្កេតការ, កម្ពុជា, pp 3-4. សូមមើល http://www2.ohchr.org/english/bodies/cat/docs/CAT.C.KHM.CO.2.pdf

នោះទេ ចាប់តាំងពីឆ្នាំ ២០១០មក។ អ្នកដែលមិនអំណោយផលច្រើនជាងគេពីការរៀបចំបែបនេះ គឺអ្នកដែល ត្រូវបានចាប់ខ្លួន។ នគរបាលបានដឹងច្បាស់ថា អ្នកឃុំឃាំងដែលងាយរងគ្រោះបំផុត គឺជាញឹកញាប់ភាគច្រើនតែងតែជាអ្នកដែលអាចសារភាពក្រោមសំពាធ ចំពោះឧក្រិដ្ឋ កម្មមួយ ឬ ឧក្រិដ្ឋកម្មច្រើន ដែលពួកគាត់មិនបានប្រព្រឹត្ត ហើយជាទូទៅពួកគាត់ មានវ័យក្មេង ឬពួកគាត់មានបញ្ហាសុខភាពផ្នែកសតិអារម្មណ៍។ ជាមួយនឹងការផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់ការសារភាព និងជនសង្ស័យដែលបានកំពុងសារភាពរួចទៅហើយ នៅក្រោមការបង្ខិតបង្ខំ ភ្នាក់ងារនគរបាលអាចព្យាយាម បង្ខំពួកគាត់អោយសារភាពចំពោះឧក្រិដ្ឋកម្មផ្សេងទៀតដែលនគរបាលដោះស្រាយមិនចេញ។

ពីព្រោះតុលាការងាយស្រួលទទួលយកលិខិតសារភាព ជាមូលដ្ឋានចំបងហើយជួន កាលជាមូលដ្ឋានតែមួយក្នុងការកាត់ក្តី ដូច្នេះនៅពេលដែលទទួលបានលិខិតសារភាព ភ្នាក់ងារនគរបាលមានទឹកចិត្តតិចតួចក្នុងការស្វែងរកភស្តុតាងគាំទ្រ។ បើសិនជាមានភស្តុតាងពិតមែន ហើយវាផ្ទុយទៅនិងការសារភាព ជាញឹកញាប់ភស្តុតាងនោះនឹងមិនត្រូវបានអើពើនោះឡើយ។

ការកើតឡើងនៃការធ្វើទារុណកម្ម និងការធ្វើបាបនៅក្នុងការឃុំឃាំងរបស់នគរបាល គឺកាន់តែធ្ងន់ធ្ងរឡើងដោយសារកត្តាផ្សេងៗទៀត។ ស្ថានភាពនៃការឃុំឃាំងនៅក្នុងបន្ទប់ឃុំឃាំងរបស់នគរបាល គឺមានសភាពអាក្រក់ ហើយអ្នកជាប់ឃុំឃាំងជាទៀងទាត់ ត្រូវបានគេបង្អត់អាហារ និងទឹកបរិភោគគ្រប់គ្រាន់។ ការទទួលបានការព្យាបាលមានសភាពកម្រ ហើយជាទូទៅមិនមានការព្យាយាមណាមួយដើម្បីបំបែករវាងអ្នកជាប់ឃុំឃាំងដែលពេញវ័យ និងអនីតិជននោះឡើយ។

មូលហេតុមួយដែលបរិយាកាសអំពើហិង្សានេះបន្តនៅតែមាន គឺដោយសាររាជរដ្ឋាភិបាលមិនអនុញ្ញាតអោយអង្គការមិនមែនរដ្ឋាភិបាល ត្រួតពិនិត្យទីកន្លែងឃុំឃាំងរបស់នគរបាល ហើយមិនមានស្ថាប័នឯករាជ្យផ្សេងទៀត ដែលត្រូវបានអនុញ្ញាត ឬមានសមត្ថភាពគ្រប់គ្រាន់ដើម្បីពិនិត្យពិច័យ និងតាមដាន ការប្រព្រឹត្ត និងស្ថានភាពជាទៀតទាត់ឡើយ។

## ទារុណកម្មដើម្បីទទួលបានចម្លើយ

សំអឿន (មិនមែនឈ្មោះគាត់ពិត) ត្រូវបាន ចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០១៣។ នៅក្រោមការឃុំឃាំងរបស់នគរបាល គាត់ត្រូវបានគេទះត្រង់មុខជាច្រើនដងហើយបន្ទាប់មកគាត់ត្រូវបានវាយ ដោយភ្នាក់ងារនគរបាល ៥នាក់ ដើម្បីទាញយកការសារ ភាព។ គាត់ត្រូវបានបង្ខំអោយបន្ទោបង់នៅ ចំពោះមុខនគរបាល ហើយគាត់ត្រូវបានគេទាត់ និងទះគ្រប់កន្លែងលើខ្លួនរបស់គាត់ រហូតដល់គាត់ដួលទៅលើដី ដែលការវាយ ដំនៅតែបន្ត។ ក្រោយមក ភ្នាក់ងារនគរបាលបានអុជដៃម្ខាងរបស់គាត់ ជាមួយនឹងភ្លើងបារី ខណៈពេលដែលអ្នកទាំងនោះ ចាប់ដៃម្ខាងទៀតរបស់គាត់ ហើយបង្ខំឲ្យគាត់ផ្តិតមេដៃលើលិខិតសារភាព។ សំអឿនមិនចេះអានអក្សរខ្មែរទេ។ ជាសរុបសំអឿន ចំណាយពេល ៣ថ្ងៃនៅក្នុងការឃុំឃាំងរបស់នគរបាល។ ក្នុងអំឡុងពេលនេះ អាជ្ញាធរមិនបានផ្តល់អាហារ ឬទឹកអោយ គាត់នោះទេហើយគាត់ពឹងផ្អែកតែមួយគត់ លើមិត្តភក្តិរបស់គាត់ក្នុងការផ្តល់ការផ្គត់ផ្គង់ចាំបាច់មកគាត់។ ប្រាក់ដែលគាត់មាននៅលើខ្លួននៅពេលដែលចាប់ខ្លួន ត្រូវបានភ្នាក់ងារនគរបាលលួច។


កងរាជអាវុធហត្ថចាប់ខ្លួនបាតុករ អំឡុងពេលបាតុកម្មក្នុង
រាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤

“..នគរបាលបានអានពាក្យសារភាព ប៉ុន្តែវាមិនមែនជាពាក្យសំដីរបស់ខ្ញុំទេ។ ខ្ញុំមិនព្រមផ្តិតមេដៃលើក្រដាសហ្នឹងទេ។ នគរបាល ស្រាប់តែវាយខ្ញុំជាមួយនិងឈើច្រត់ ចំស្មាខ្ញុំ និងខ្នងខ្ញុំ... ទោះបីជាខ្ញុំប្រាប់គាត់ថាខ្ញុំមានផ្ទៃពោះ...”

ស្ត្រីម្នាក់ ដែលបានរាយការណ៍ពីការបំពាននៅប៉ុស្តិ៍
នគរបាលភ្នំពេញ កាលពីឆ្នាំ២០១៣

# ការវាយដំក្នុងពេលចាប់ខ្លួន និងពេលបញ្ជូនខ្លួន

ប្រហែលជាប្រភេទអំពើហិង្សា ទៅលើអ្នកជាប់ឃុំឃាំង ដែលសាមញ្ញបំផុត ជាក់ស្តែងបំផុត ប៉ុន្តែត្រូវបានរាយការណ៍តិចបំផុត គឺជាប្រភេទហិង្សា ដែលកើតឡើងនៅពេលចាប់ខ្លួន។ អំពើ ហិង្សានេះអាចកើតឡើងនៅក្នុងផ្ទះជនសង្ស័យ នៅកន្លែងធ្វើការរបស់គាត់ ឬនៅតាមដងផ្លូវ។ សាក្សីជាញឹកញាប់តែងតែមានវត្តមាននៅកន្លែងនៃការបំពាន ប៉ុន្តែមន្ត្រីទាំងនោះ កម្រត្រូវបានកោះហៅទៅទទួលខុសត្រូវ។

យោងតាមចំលើយរបស់សាក្សីដែលអង្គការ លីកាដូ ទទួលបានការបំពានបែបនេះ ជាញឹកញាប់ គឺធ្វើតាមតែអំពើចិត្ត មិនចាំបាច់ ហើយមិនសមរម្យ ចំពោះឧក្រិដ្ឋកម្មដែលបានអះអាង ឬក៏ការគម្រាមណាមួយដែលអាចកើតមានឡើងចំពោះមន្ត្រី ប៉ុន្តែអំពើហិង្សានេះអាចជាការធ្វើឲ្យស្របច្បាប់មិនត្រឹមត្រូវ នៅក្រោមឈ្មោះជាការការពារច្បាប់ និងសណ្តាប់ធ្នាប់។ មានការយកចិត្តទុកដាក់តិចតួច ឬមិនមានទាល់តែសោះ ចំពោះតម្រូវការចាំបាច់ក្នុងការបន្ធូរបន្ថយរបួសស្នាមហើយអ្នករងគ្រោះទាំងនោះជាញឹកញាប់ត្រូវរងចាំរយៈពេលយូរមុនពេលពួកគេទទួលបានការព្យាបាលណាមួយ។

នៅក្នុងករណីមួយនៃករណី ដែលលេចធ្លោបំផុតក្នុងឆ្នាំ២០១៤ មេដឹកនាំសហជីព ២៣នាក់ និងកម្មករច្រើននាក់ ត្រូវបានគេចាប់ខ្លួនដោយហិង្សា នៅកំឡុងពេលការប៉ះទង្គិចយ៉ាងខ្លាំងនៅដើមខែមករា ឆ្នាំ២០១៤[៧] ។ មនុស្សជាច្រើននាក់ត្រូវបានវាយដំយ៉ាងធ្ងន់ធ្ងរនៅក្នុងពេលចាប់ខ្លួន និងត្រូវបានកាត់ទោសភ្លាមៗ ហើយអ្នកទាំងនោះ ត្រូវបានឃុំឃាំងទុករយៈពេលច្រើនថ្ងៃដោយគ្មានមធ្យោបាយទាក់ទង ហើយអ្នកទាំងនោះ ក៏ត្រូវបានគេបដិសេធក្នុងការទទួលបានសេវាពេទ្យឯករាជ្យណាមួយ។ អ្នកទាំងនោះ មួយចំនួនត្រូវការការព្យាបាល ដោយសារតែគាត់ទទួលរងរបួសនៅពេលចាប់ខ្លួន ហើយអជ្ញាធរបន្តការមិនយកចិត្តទុកដាក់ចំពោះតម្រូវការផ្នែកសុខភាពរបស់ពួកគាត់ក្នុងអំឡុងពេលជាប់ឃុំឃាំង។


យោធាវាយបាតុករដោយដំបងដែក អំឡុងពេលចាប់ខ្លួនមួយ ក្បែររោងចក្រយ៉ាក ជីង ក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០១៤

"...នៅម៉ោង ៦.៣០នាទីព្រឹក ខ្ញុំទៅខាង ក្រៅ ដើម្បីទៅបង្គន់។ នៅពេលខ្ញុំត្រលប់ មកវិញ មាននគរបាល ពី៣០ ទៅ៤០នាក់ ព័ទ្ធជុំវិញ ផ្ទះរបស់ខ្ញុំ។ គ្នាគាត់ ៨នាក់ ចាប់ខ្លួនខ្ញុំ វាយខ្ញុំ ហើយចាប់ខ្ញុំឆក់ភ្លើង រហូតដល់ខ្ញុំបាត់បង់ស្មារតី (សន្លប់)។ នៅពេលដែលខ្ញុំដឹងខ្លួននៅឡាន ប៉ូលីស ពួកគេឆក់ខ្ញុំម្តងទៀតរហូតដល់ខ្ញុំបាត់បង់ ស្មារតី (សន្លប់) ម្តងទៀត។"

បុរសម្នាក់ ដែលបានរាយការណ៍ពីការបំពាន ដោយភ្នាក់ងារនគរបាលខេត្ត កាលពីឆ្នាំ២០១០។

ក្នុងអំឡុងពេលសវនាការរបស់អ្នកទាំងនោះ ដែលបានប្រព្រឹត្តិទៅប្រាំថ្ងៃដាច់ៗពីគ្នាការព្យាយាមស្ទើរតែទាំងអស់របស់មេធាវីចុង ចោទ ដើម្បីបង្ហាញភស្តុតាងនៃអំពើហិង្សាទៅលើអ្នកទាំង ២៣នាក់ នៅពេលចាប់ខ្លួន ត្រូវបានបដិសេធភ្លាមៗ ដោយតុលាការ និង ព្រះរាជអាជ្ញា។ រហូតមកដល់ថ្ងៃនេះ មិនមានសកម្មភាពណាមួយត្រូវបានធ្វើឡើង ដើម្បីដាក់ទោសអ្នកដែលជាអ្នកបង្កអំពើហិង្សា កាលពីថ្ងៃទី២ និងទី៣ ខែមករា ដែលបានធ្វើអោយមនុស្សយ៉ាងតិច ៤នាក់បាត់បង់ជីវិតនោះឡើយ[៨]។អ្នកទាំង ២៣នាក់ ព្រម ទាំងមនុស្សពីរនាក់ផ្សេងទៀត ដែលត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលការបង្ក្រាបដោយហិង្សាលើការធ្វើបាតុកម្មមួយ នៅខែវិច្ឆិកា ឆ្នាំ២០១៣ នៅទីបញ្ចប់ អ្នកទាំងនោះ ត្រូវបានកាត់អោយជាប់ទោស ប៉ុន្តែត្រូវបានផ្តល់ការព្យួរទោស[៩] ។

ជាធម្មតាក៏មានការបំពានផងដែរ ក្នុងពេលបញ្ជូនទៅកាន់កន្លែងឃុំឃាំងរបស់នគរបាល ហើយពេលខ្លះ មន្ត្រីចាប់ផ្តើមដំណើរការសួរចម្លើយនៅក្នុងដំណាក់កាលនេះ ដើម្បីទាញយកផលប្រយោជន៍ពីសភាពរបស់ជនសង្ស័យ ដែលកំពុងតែចាប់ផ្តើមតក់ស្លុត និងងាយរងគ្រោះ។

[៧] សម្រាប់ពត៌មានបន្ថែមសូលមើលសេចក្តីថ្លែងការណ៍រួម "កម្ពុជា៖ ការរំខាន ការឃាត់ខ្លួន និងការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សនៅតែបន្តកើតមានឡើង", ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤៖ http://www.licadho-cambodia.org/pressrelease.php?perm=339
[៨] ខែម សុផាត ដែលមាន ១៥ឆ្នាំ បានបាត់ខ្លួនតាំងពីថ្ងៃទី ៣ ខែមករា។ គាត់ត្រូវបានឃើញចុងក្រោយបំផុត ដោយគាត់ដេកនៅលើផ្លូវវេងស្រេងជាមួយនិងរបួសកាំភ្លើងត្រង់ទ្រូងរបស់គាត់។ បុគ្គលទី៦ ដែលត្រូវបានវាយដោយទាហាននគរបាល នៅថ្ងៃទី៣ ខែមករា បានស្លាប់បន្ទាប់ពី ៤ខែក្រោយ។ របាយការណ៍ខ្លះនិយាយថាការស្លាប់របស់គាត់គឺទាក់ទងនិងរបួសដែលគាត់ទទួលរងកំឡុងពេលអំពើហិង្សា : http://www.cambodiadaily.com/news/worker-beaten-on-veng-sreng-in-january-dies-of-head-injuries-58976/
[៩] សម្រាប់ពត៌មានបន្ថែមសូមមើលការចេញផ្សាយរបស់លីកាដូ "សាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសកម្មករ និងសកម្មជនសិទ្ធិទាំង ២៥នាក់ ប៉ុន្តែទោសនៅសល់ត្រូវព្យួរ", ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤៖ http://www.licadho-cambodia.org/pressrelease.php?perm=344

# ការបំពានដែលមិនបានរាយការណ៍

ករណីនៃភាពសាហាវព្រៃផ្សៃ ដែលបានកត់ត្រាដោយអង្គការ លីកាដូ គឺជាការបញ្ជាំងអោយឃើញពីទម្រង់ទូលំទូលាយនៃអំពើហិង្សា ដែលមិនបានរាយការណ៍។ អង្គការ លីកាដូ មិនអាចសម្ភាសន៍អ្នកដែលនៅក្នុងការឃុំឃាំងរបស់នគរបាលបានទេ ហើយភាគច្រើននៃបទសម្ភាសន៍ គឺធ្វើឡើងនៅក្រោមបរិយាកាសពន្ធនាគារ ដែលទទួលរងការបង្ខិតបង្ខំ ដែលអ្នកជាប់ឃុំឃាំងជាច្រើនអ្នកមានការភ័យខ្លាចយ៉ាងខ្លាំងក្នុងការប្តឹងតវ៉ា អំពីការធ្វើបាបដោយសារអាជ្ញាធរ។ ម្យ៉ាងទៀត អ្នកស្រាវជ្រាវរបស់អង្គការ លីកាដូ អាចជួបបានត្រឹមតែចំណែកមួយភាគតូច នៃអ្នកជាប់ពន្ធនាគារទាំងអស់ដែលនៅក្នុងពន្ធនាគារចំនួន ១៨កន្លែង នៃពន្ធនាគារទាំង ២៨ កន្លែងក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។



ការចាប់ខ្លួនអនីតិជនពីសំណាក់កងនគរបាល អំឡុងពេលបាតុកម្មក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣

យោងតាមបទសម្ភាសន៍របស់អង្គការ លីកាដូ នេះពិតប្រាកដណាស់ ដែលភាពព្រៃផ្សៃរបស់នគរបាលមិនត្រូវបានរាយការណ៍ ពីព្រោះអំពើទាំងនេះត្រូវបានចាត់ទុកថាជាឥរិយាបទធម្មតា។ មនុស្សជាច្រើនដែលទទួលរង ឬបានប្រទះឃើញការប្រព្រឹត្តបែបនេះ បានរាយការណ៍ថាពួកគេ ឬអ្នកឯទៀត "គ្រាន់តែ" ត្រូវបានវាយ ឬទាត់ និងដាល់ "ត្រឹមតែ" ពីរបីដងប៉ុណ្ណោះ។មនុស្សមួយចំនួនបានបញ្ជាក់ថា ថ្វីបើពួកគាត់ទទួលរងការវាយដំបែបនេះក៏ដោយ គាត់មិនបានគិតថាពួកគាត់ត្រូវបានគេធ្វើបាបអាក្រក់ណាស់ណាទេ។

ខណៈដែលរបាយការណ៍អំពីការធ្វើទារុណកម្ម និងការធ្វើបាបដោយអាជ្ញាធរពន្ធនាគារ មិនសូវជាមានច្រើន តែគួរអោយកត់សំគាល់ថា ជាទូទៅអ្នកជាប់ពន្ធនាគារមិនសូវជាប្តឹងអំពីការបំពាននៅពេលដែលវាកើតឡើងនៅកន្លែងដែលពួកគាត់ត្រូវបានឃុំខ្លួន និងនៅពេលដែលពួកគាត់នៅក្រោមការគ្រប់គ្រងរបស់អ្នក ដែលបំពានពួកគាត់នៅឡើយ។ ជាញឹកញាប់អង្គការ លីកាដូ តែងតែទទួលបានរបាយការណ៍អំពីការបំពាន ក្រោយពេលដែលអ្នកជាប់ពន្ធនាគារត្រូវបានដោះលែងតែប៉ុណ្ណោះ។

នៅក្នុងបរិបទនេះ អង្គការ លីកាដូ ក៏បានកត់សំគាល់ផងដែរថា ការដាក់កម្រិតចំពោះការទៅសួរសុខទុក្ខរបស់អង្គការ លីកាដូ នៅពន្ធនាគារបានកំពុងកើនឡើង។ អ្នកស្រាវជ្រាវរបស់អង្គការ លីកាដូ មិនអាចទៅសួរសុខទុក្ខនៅពន្ធនាគារ ដោយគ្មានការផ្តល់ដំណឹងមុន ហើយពេលខ្លះ ពួកគាត់មិនអាចធ្វើបទសម្ភាសន៍នៅក្នុងពន្ធនាគារដោយធានាការសម្ងាត់ពេញលេញនោះទេ។ នៅក្នុងព្រឹត្ត-ការណ៍បែបនេះ អង្គការ លីកាដូ មិនអាចសួរសំនួរដែលអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់អ្នកជាប់ពន្ធនាគារ ឬធ្វើអោយប៉ះពាល់ដល់ស្ថានភាពឃុំឃាំងរបស់អ្នកនោះ នោះទេ។

ទណ្ឌិត ដែលត្រូវបានដោះលែងមួយចំនួនបានប្រាប់អង្គការ លីកាដូ ថាពួកគាត់ត្រូវបានគេគំរាមកំហែង មុនពេលការទៅសួរសុខទុក្ខនៅពន្ធនាគាររបស់អង្គការ លីកាដូ និងអង្គការផ្សេងទៀត។ ហើយអ្នកឯទៀតបានរាយការយ៍ថាពួកគាត់ត្រូវបានអាជ្ញាធរ ឬមេបន្ទប់ក្នុងពន្ធនាគារ សួរចំលើយ បន្ទាប់ការសួរសុខទុក្ខបែបនេះ។ អង្គការ លីកាដូ ក៏បានទទួលរបាយការណ៍ផងដែរ អំពីអ្នកជាប់ពន្ធនាគារដែលនៅពេលដោះលែង គាត់ត្រូវបានគេផ្តល់លុយរួមជាមួយ និងការព្រមព្រៀង ថាពួកគាត់នឹងមិននិយាយជាមួយអង្គការមិនមែនរដ្ឋាភិបាលអំពីជីវិតនៅក្នុងគុកឡើយ។

"ខ្ញុំត្រូវបានគេដាក់ខ្នោះ និងដាក់ច្រវាក់ទៅនឹងឡាន...ក្រុមនគរបាលប្រាំនាក់បានសួរចម្លើយខ្ញុំ... អ្នកទាំងនោះព្យាយាមសម្លុត និងបញ្ចុះបញ្ចូលខ្ញុំអោយសារភាពចំពោះបទល្មើសជាច្រើនផ្សេងៗគ្នា។ នៅពេលដែលខ្ញុំមិនយល់ព្រម ពួកគេឈប់ឡាន ហើយទាត់ខ្ញុំចេញ ធ្វើអោយខ្ញុំឈឺយ៉ាងខ្លាំងនៅត្រង់កញ្ចឹងក"។

បុរសម្នាក់ ដែលបានរាយការណ៍អំពីការបំពាន ដោយភ្នាក់ងារនគរបាលខេត្ត កាលពីឆ្នាំ២០០៩

មានអង្គការចំនួនបី ដូចជាអង្គការ លីកាដូ គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (UNOHCHR) ដែលបានធ្វើការតាមដានស្ថានភាពក្នុងការឃុំខ្លួនយ៉ាងច្បាស់លាស់ និងលំអិត ជាងការតាមដានពិនិត្យរបស់ប៉ុស្តិ៍នគរបាល។ ការពិនិត្យ តាមដាននេះ រួមផ្សំជាមួយនិងការពង្រឹងវគ្គបណ្តុះបណ្តាលដល់ឆ្មាំ ពន្ធនាគារបាននាំអោយមកនូវការកាត់បន្ថយពិតប្រាកដនៃអំពើហិង្សានៅក្នុងពន្ធនាគារ ដែលបង្កដោយមន្ត្រីពន្ធនាគារ។ ប៉ុន្តែអ្នកស្រាវ ជ្រាវរបស់អង្គការ លីកាដូ បានបង្ហាញផងដែរថា វប្បធម៌នៃការបំពាននៅក្នុងពន្ធនាគារ គឺមានភាពស្មុគស្មាញច្រើនជាងការបំពាននៅក្នុងការឃុំឃាំងរបស់នគរបាល។

ផ្ទុយពីអំពើសាហាវព្រៃផ្សៃដែលឃើញច្បាស់លាស់ មានរយៈពេលខ្លី និងពេលខ្លះកើតឡើងមិនបានគ្រោងទុក ដែលបានកើតឡើងនៅ ក្នុងការឃុំឃាំងរបស់នគរបាល ការបំពាននៅក្នុងពន្ធនាគារទំនងជាមានការស្ថិតថេរ ការកំណត់គោលដៅច្បាស់លាស់ និងរៀបចំទុកមុន។

ដូចគ្នានេះដែរ ខណៈពេលដែលការបំពានរបស់នគរបាលដែលជាធម្មតាជំរុញដោយមូលហេតុផ្នែកហិរញ្ញវត្ថុ ឬសម្ពាធ ដើម្បីទទួលបានការកាត់ទោស នៅក្នុងពន្ធនាគារ មនុស្សម្នាក់ៗប្រហែលជាទទួលរងការធ្វើបាប ដោយសារតែស្ថានភាពរបស់អ្នកទាំងនោះម្នាក់ៗ ឬ ដោយសារសកម្មភាព និងឋានៈនៅក្នុងពន្ធនាគាររបស់គាត់។

ជាចុងក្រោយ ខណៈពេលដែលអ្នកប្រព្រឹត្តិបទល្មើសនៃការបំពាននៅក្នុងទីស្នាក់នគរបាល ជាធម្មតាបានធ្វើសកម្មភាព ដោយឆន្ទៈរបស់ពួកគេផ្ទាល់នៅក្នុងពន្ធនាគារ ការវាយដំ និងការដាក់ទណ្ឌកម្មផ្សេងៗទៀត គឺជាញឹកញាប់ត្រូវបានធ្វើឡើងដោយអ្នកជាប់ពន្ធនាគារដ៏ទៃទៀត នៅក្រោមបញ្ជានៃអាជ្ញាធរពន្ធនាគារ។ កិច្ចការនេះជាធម្មតាធ្លាក់ទៅលើមេបន្ទប់ក្នុងពន្ធនាគារ ដែលត្រូវបានចាត់តាំងដែលជាអ្នកដែលត្រូវបានជ្រើសរើសដោយអាជ្ញាធរពន្ធនាគារ ដើម្បីរក្សាសណ្តាប់ធ្នាប់ និងវិន័យនៅក្នុងបន្ទប់នីមួយៗ។

# អ្នកជាប់ពន្ធនាគារបំពានលើអ្នកជាប់ពន្ធនាគារ

អង្គការ លីកាដូ បាននិយាយជាមួយអ្នកជាប់ពន្ធនាគារជាច្រើននាក់ រួមមានទាំងអនីតិជន ដែលបានរាយការណ៍ថាពួកគាត់ត្រូវបានបំពានដោយអ្នកជាប់ពន្ធនាគារដូចគ្នា ដែលពេលខ្លះកើត ឡើងដោយញុះញង់ ឬដោយមានការអនុញ្ញាត ឬការយល់ព្រមពីអជ្ញាធរពន្ធនាគារ។ ការវាយដំបែបនេះ ដែលមិនមែនជាការភ្ញាក់ផ្អើលមានការកើតឡើងតិចតួចក្នុងចំណោមអ្នកទោសជាស្ត្រី។

ប្រធានបន្ទប់មួយចំនួន ដែលជាអ្នកទទួលខុសត្រូវលើការអនុវត្ត ឬការបញ្ជាអោយមានការវាយដំ បន្ទាប់ពីត្រូវបានដោះលែងពីពន្ធនារគារ អ្នកទាំងនោះបានប្រាប់ដល់អង្គការ លីកាដូ ថា អ្នកទាំងនោះជាអ្នកបំពាន។

អ្នកជាប់ពន្ធនាគារ និងអតីតអ្នកជាប់ពន្ធនាគារបានរាយ-ការណ៍មូលហេតុជាច្រើន អំពីការបំពានរបស់អ្នកជាប់ពន្ធនាគារលើអ្នកជាប់ពន្ធនាគារ។ ពិធីវាយដំដើម្បីបញ្ចូលសមាជិកថ្មី សម្រាប់អ្នកជាប់ពន្ធនាគារដែលមកដល់ថ្មី គឺជារឿងទូទៅ ហើយជាញឹកញាប់ គឺតំរង់ទិសទៅរកអ្នកជាប់ពន្ធនាគារដែលវ័យក្មេង ក្រីក្រ ឬទន់ ខ្សោយ។

អំពើហិង្សាក៏ជាទម្រង់ទូទៅមួយផងដែរនៃការដាក់ទណ្ឌកម្មទៅលើអ្នកដែលធ្វើខុសនិងវិន័យបន្ទប់ ដូចជាការត្រលប់មកបន្ទប់យឺតយ៉ាវបន្ទាប់ពីម៉ោងលំហែកាយ។ អ្នកជាប់ពន្ធនាគារក៏ត្រូវទទួលទណ្ឌកម្ម ប្រសិនបើល្មើសនឹងវិន័យផ្ទាល់មាត់ផងដែរ។ ឧទាហរណ៍ អតីតអ្នកទោសម្នាក់ បានរៀបរាប់អំពីការវាយប្រហារដោយប្រធាន បន្ទប់ទៅលើមិត្តរួមបន្ទប់របស់គាត់ ដោយសារអ្នកទោសនោះ មិនព្រមលះបង់កន្លែងដំណេករបស់គេ ដើម្បីបើកផ្លូវអោយអ្នកទោសម្នាក់ដែលមានប្រាក់ច្រើនជាង។ អ្នកទោសម្នាក់ទៀត ត្រូវបានវាយ ដោយសារតែប្រធានបន្ទប់បានកំណត់ ថាគាត់បាននិយាយឡូឡាខ្លាំងពេកនៅពេលយប់។

អ្នកជាប់ពន្ធនាគារមួយចំនួន ដែលត្រូវបានវាយដោយអ្នកជាប់ពន្ធនាគារដូចគ្នាបានប្រាប់អង្គការ លីកាដូថា ពួកគាត់មិនបានចាត់ទុកថា នេះគឺជាអំពើធ្ងន់ធ្ងរ ឬមិនធម្មតានោះទេ។ ភាពធម្មតា នៃពិធីវាយដំដើម្បីបញ្ចូលសមាជិកថ្មី និងអំពើហិង្សារបស់អ្នកជាប់ពន្ធនាគារលើអ្នកជាប់ពន្ធនាគារ ហាក់បីដូចជាឆ្លុះបញ្ចាំងពីទស្សនៈនៃអំពើឃោរឃៅរបស់នគរបាល ថាជាអ្វីដែលត្រូវបានរំពឹងទុក ជាមុន និងត្រូវទទួលយក ហើយពិតណាស់ជាអ្វីដែលមិនគួរឲ្យប្តឹង ឬរាយការណ៍នោះទេ។

> “ពួកគេបានវាយ ទះ និងទាត់ ដូចធ្វើដាក់ជាមួយអ្នកទោសពេញវ័យ...ធម្មតាអ្នកយាមមិនដែលវាយអ្នកទោសដោយផ្ទាល់ដៃទេ ពួកគេប្រើអ្នកជាប់ពន្ធនាគារផ្សេងទៀតអោយវាយ។”
>
> អ្នកជាប់ពន្ធនាគារជាអនិតិជនភេទប្រុសម្នាក់ ដែលបានរាយការណ៍ពីការបំពាននៅក្នុងពន្ធនាគារខេត្ត ចន្លោះពីឆ្នាំ២០១២ ដល់ ២០១៣

វប្បធម៌នៃភាពភ័យខ្លាច និងភាពសង្ស័យ ក៏បានរាលដាលទៅលើជីវិតនៅក្នុងបន្ទប់ក្នុងពន្ធនាគាររបស់ប្រទេសកម្ពុជា ដែលប្រធានបន្ទប់ នឹងអ្នកជាប់ពន្ធនាគារឯទៀត ជួនកាលមិនស្គាល់មុខត្រូវបានរាយការណ៍ថា ពួកគេបានដើរតួជាភ្នែក និងត្រចៀកអោយឆ្មាំពន្ធនាគារ។ ចំពោះកត្តាដ៏ទៃផ្សេងៗទៀតនៃវប្បធម៌ពន្ធនាគារ អ្នកដែលមានប្រាក់ គឺតែងតែត្រូវបានជ្រើសរើសអោយរងការបំពានតិចជាងអ្នកឯទៀត។

# ការដាក់ទណ្ឌកម្មដោយសារការដាក់ពាក្យបណ្តឹង

ប្រសិនបើអ្នកជាប់ពន្ធនាគារព្យាយាមដាក់ពាក្យបណ្តឹងអំពីការប្រព្រឹត្តទៅលើពួកគេ អំពីស្ថានភាពឃុំឃាំងរបស់ពួកគេ ឬឥរិយាបថនៃអ្នកជាប់ពន្ធនាគារឯទៀត គឺអ្នកទាំងនោះអាចទទួលគ្រោះថ្នាក់។ ឧទាហរណ៍ដូចជា នៅក្នុងឆ្នាំ២០១១ អង្គការលីកាដូ បានសម្ភាសន៍អ្នកជាប់ពន្ធនាគារម្នាក់ ដែលត្រូវបានវាយដំដោយអាជ្ញាធរពន្ធនាគាររយៈពេល ៥ដងផ្សេងៗគ្នា បន្ទាប់ពីគាត់បានប្តឹងអំពីគុណភាពនៃទឹកទទួលទាននៅក្នុងពន្ធនាគារ។ អតីតអ្នកទោសជារឿយៗតែងតែប្រាប់អង្គការ លីកាដូ ថាកាលពួកគាត់ នៅ ក្នុងពន្ធនាគារ ពួកគេមិនហានប្តឹងតវ៉ាទេ។ នៅក្នុងបរិយាកាសនេះមិនគួរឲ្យភ្ញាក់ផ្អើលទេ ដែលការធ្វើបាបនៅក្នុងពន្ធនាគារ ដែលជាញឹកញាប់មិនត្រូវបានរាយការណ៍។

អ្នកដែលបានប្តឹងអំពីការបំពាន បើល្អបំផុតគឺត្រូវបានគេមិនរវីរវល់ ហើយបើអាក្រក់បំផុតគឺត្រូវបានរងការធ្វើបាបបន្ថែមទៀត។ ប្រធានបន្ទប់ទាំងនោះដែលបដិសេធមិនព្រមធ្វើតាមបញ្ជា អ្នកទាំងនោះ អាចនឹងត្រូវបានវាយ ឬមិនដូច្នោះទេ គឺត្រូវបានដាក់ទណ្ឌកម្ម។

នៅក្នុងឱកាសមួយទៀត អ្នកជាប់ពន្ធនាគារដដែលនេះ បានប្តឹងអំពីការចែកចាយរបបអាហារមិនស្មើភាព ហើយគាត់ត្រូវបានវាយដោយអ្នកជាប់ពន្ធនាគារដទៃទៀត។ យោងតាមសំដីគាត់ អ្នកជាប់ពន្ធនាគារដែលវាយគាត់នោះមានទំនាក់ទំនងចិត្តស្និតជាមួយនឹងឆ្មាំពន្ធនាគារ។ នៅពេលដែលគាត់រាយការណ៍អំពីការវាយដំទាំងនោះ មិនមានសកម្មភាពណាមួយត្រូវបានធ្វើឡើងនោះទេ។



ឆ្មាំពន្ធនាគារ និងអ្នកទោសក្នុងពន្ធនាគារកម្ពុជា ឆ្នាំ២០០៩

## ប្រធានបន្ទប់

អង្គការ លីកាដូ បាននិយាយជាមួយអ្នកទោសវ័យក្មេងម្នាក់ឈ្មោះ លីដា (មិនមែនឈ្មោះពិតរបស់គាត់) ដែលបន្ទាប់ពី ៦ខែនៅក្នុងពន្ធនាគារ គាត់ត្រូវបានតែងតាំងធ្វើជាប្រធានបន្ទប់អ្នកជាប់ពន្ធនាគារជាអនីតិជន ដោយឆ្មាំពន្ធនាគារ។ លីដាបានធ្វើជាប្រធានបន្ទប់រយៈពេល ២ឆ្នាំ មុនពេលគាត់ត្រូវបានឡើងឋានៈជាគណៈកម្មាធិការគ្រប់គ្រងបន្ទប់ ដែលមានឋានៈជាអ្នកដឹកនាំអ្នកជាប់ពន្ធនាគារ ដែលមានអំណាចក្នុងការគ្រប់គ្រង និងអប់រំប្រធានបន្ទប់។ មុខតំណែងរបស់គាត់បាននាំមកជាមួយផលប្រយោជន៍សំខាន់ៗ រួមមានដូចជារយៈពេលនៅខាងក្រៅបន្ទប់ច្រើនជាងមុន ហើយរបបអាហារបន្ថែម ប៉ុន្តែក៏មានផ្នែកអាក្រក់ផងដែរ។

ជាមួយនិងការទទួលខុសត្រូវក្នុងការរាយការណ៍ការចលាចលក្នុងបន្ទប់ ការគ្រប់គ្រងការងារពលកម្មរបស់ពន្ធនាគារ និងត្រួតពិនិត្យអ្នកទោសឈឺ ក្រៅពីនេះវាមានមកជាមួយនិងកិច្ចការនៃការវាយដំទណ្ឌិតថ្មី ឬអ្នកដែលត្រលប់មកបន្ទប់យឺតយ៉ាវ។ ប្រធានបន្ទប់ដែលបានធ្វើខុស និងអ្នកដែលមិនបានអនុវត្តន៍តាមបញ្ជានឹងត្រូវបានវាយដំ ដោយគណៈកម្មាធិការគ្រប់គ្រងបន្ទប់ ឬដោយឆ្មាំពន្ធនាគារ។

> “នៅពេលដែលខ្ញុំរាយការណ៍អំពីល្បែងស៊ីសងទៅមន្ត្រីពន្ធនាគារ ខ្ញុំត្រូវបានវាយដំ ដោយអ្នកជាប់ពន្ធនាគារដទៃទៀត។ នៅពេលដែលខ្ញុំប្តឹងអំពីរឿងនេះទៅមន្ត្រីពន្ធនាគារ ពួកគេមិនខ្វល់ទេ ឬ ធ្វើសកម្មភាពអ្វីទេ ពីព្រោះអ្នកដែលលេងល្បែងគឺអ្នកជាប់ពន្ធនាគារដែលមានប្រាក់។ អ្នកដែលធ្វើសកម្មភាពវាយដំមិនដែលត្រូវទណ្ឌកម្មទេ។ ឆ្មាំពន្ធនាគារគម្រាមថានឹងបញ្ជូនខ្ញុំទៅពន្ធនាគារ ម១ បើសិនជាខ្ញុំធ្វើការប្តឹងបន្តទៀត។ គ្មាននរណា ម្នាក់ហ៊ានរាយការណ៍អំពីបញ្ហាអ្វីទេ។ ខ្ញុំស្គាល់មនុស្សប្រាំនាក់ផ្សេងទៀតដែលត្រូវបានគេបញ្ជូនទៅពន្ធនាគារ ម៣ បន្ទាប់ពីពួកគាត់បានដាក់ពាក្យបណ្តឹង”

បុរសម្នាក់ ដែលបានរាយការណ៍អំពីការបំពាននៅក្នុងពន្ធនាគារខេត្ត ចន្លោះពីឆ្នាំ២០១០ ដល់ ២០១៣

# ការបំពាន និងការផ្សំគំនិតរបស់អាជ្ញាធរពន្ធនាគារ

ខណៈពេល ដែលភាគច្រើននៃអំពើហិង្សាលើអ្នកទោសដែលបានរាយការណ៍ទៅអង្គការ លីកាដូ គឺបង្កឡើងដោយសារស្នាដៃអ្នកទោសដូចគ្នា ដោយគាត់ធ្វើឡើងដោយចិត្តខ្លួនឯង ឬនៅក្រោមការបញ្ជានៃអាជ្ញាធរ ។ក្រៅពីនេះអង្គការ លីកាដូ ក៏ទទួលបានសាក្ខីភាពអំពីការបំពានផ្លូវកាយ និងសំដី បង្កដោយមន្ត្រីពន្ធនាគារ។ តាំងពីឆ្នាំ២០០៨ អង្គការ លីកាដូ បានកត់ត្រាការបំពានផ្លូវកាយ ដែលបង្កដោយមន្ត្រីពន្ធនាគារនៅក្នុងពន្ធនាគារ១៣ កន្លែង ក្នុងចំនោមពន្ធនាគារចំនួន ១៨កន្លែងដែលអង្គការ លីកាដូ បានតាមដាន។

ឧទាហរណ៍ដូចជា នៅក្នុងខែមេសា ឆ្នាំ២០១៣ ឆ្មាំពន្ធនាគារម្នាក់បានវាយអ្នកជាប់ពន្ធនាគារម្នាក់ បន្ទាប់ពីការជជែកឈ្លោះគ្នាលើផ្លែស្វាយមួយចំនួន ដែលអ្នកទោសបានយកមកពីចំការមួយនៅក្បែរចំការកៅស៊ូ ដែលគាត់និងអ្នកទោសឯទៀតបានទៅធ្វើការ។ យោងតាមរបាយការណ៍ អ្នកយាមគុកបានដាល់អ្នកទោសនោះធ្វើអោយគាត់ដួលទៅលើថ្ម។ ជាលទ្ធផលគាត់ទទួលរងស្នាមមុតជាច្រើននៅលើមុខរបស់គាត់ និងត្រូវការការដេរភ្ជិតមុខរបួសចំនួន ១៥ថ្នេរ ។

នៅក្នុងឧទាហរណ៍ដ៏កម្រមួយ ដែលមន្ត្រីម្នាក់ទទួលការពិន័យនូវទម្រង់ជាច្រើន ចំពោះអំពើហិង្សារបស់ខ្លួនទៅលើអ្នកជាប់ឃុំឃាំងឆ្មាំពន្ធនាគារ ដែលមានជាប់ទាក់ទងបានទទួលនូវការពិន័យជាប្រាក់ ហើយត្រូវដកហូតពីតួនាទីទាំងឡាយណាដែលជាប់ទាក់ទងដោយផ្ទាល់ជាមួយនឹងអ្នកជាប់ពន្ធនាគារ។ ប៉ុន្តែ ទោះជាគាត់ត្រូវបានសួរចម្លើយដោយព្រះរាជអាជ្ញារងក៏ដោយ ក៏មិនមានវិធានការដាក់វិន័យណាមួយផ្សេងទៀតត្រូវបានធ្វើឡើងទៅលើរូបគាត់នោះឡើយ។

អង្គការ លីកាដូ មិនបានរកឃើញការដាក់ពិន័យណាមួយទៅ លើមន្ត្រីពន្ធនាគារ នៅក្នុងករណីការបំពានដែលបានរាយការណ៍ថ្មីៗនោះឡើយ ពីព្រោះដោយសារតែអ្នកទោសមានការស្ទាក់ស្ទើរ ឬមិនអាចធ្វើការដាក់ពាក្យបណ្តឹងជាផ្លូវការ ឬ ពីព្រោះពាក្យបណ្តឹងដែល បានដាក់មិនត្រូវបានយកចិត្តទុកដាក់ ឬមិនត្រូវបានធ្វើការស៊ើបអង្កេតត្រឹមត្រូវ។

អ្នកដែលបានព្យាយាមរត់ចេញពីពន្ធនាគារ ឬអ្នកដែលបានរត់គេចខ្លួចរួច ហើយត្រូវបានចាប់មកវិញ គឺជាទៀងទាត់ទទួលរងការជាប់ឃុំឃាំងនៅក្នុងពន្ធនាគាររយៈពេលយូរ ហើយនឹងទទួលរងការវាយដំធ្ងន់ធ្ងរ និងទណ្ឌកម្មឃោរឃៅផ្សេងទៀត។ អង្គការ លីកាដូ បានកត់ត្រាករណីបួន ដែលមានលក្ខណៈបែបនេះ នៅក្នុងឆ្នាំ២០១២ តែមួយគត់។ អ្នកទាំងនេះ មិនមានឱកាសដើម្បីដាក់ពាក្យបណ្តឹងទាន់ពេលអំពីការបំពានទៅលើពួកគាត់ ពីព្រោះពួកគាត់ជាទូទៅត្រូវបានដាក់ឃុំឃាំងដាច់ពីពិភពខាងក្រៅរយៈពេល ច្រើនសប្តាហ៍ ឬច្រើនខែ។ អ្នកស្រាវជ្រាវរបស់អង្គការ លីកាដូ ជាញឹកញាប់តែងតែត្រូវគេបដិសេធក្នុងការជួបជាមួយអ្នកទាំងនោះជារឿយៗ។

អ្នកជាប់ពន្ធនាគារជាស្ត្រី ក៏បានត្រូវបានទទួលរងការបំពានដោយមន្ត្រីពន្ធនាគារផងដែល។ នៅក្នុងឆ្នាំ២០១១ ស្ត្រីមានផ្ទៃពោះបួនខែម្នាក់បានរាយការណ៍ប្រាប់អង្គការ លីកាដូ ថាឆ្មាំពន្ធនាគារម្នាក់បានវាយចំខ្នងខាងក្រោមរបស់គាត់ ជាមួយនឹងដំបងឈើ ហើយបានប្រាប់គាត់ថាគេវាយគាត់ "សម្រាប់ការសប្បាយ"។ ពាក្យបណ្តឹងរបស់គាត់ចុងក្រោយត្រូវបានបញ្ជូនទៅប្រធានពន្ធនាគារជាអ្នក ដែលបានយល់ព្រមផ្លាស់ប្តូរតែតួនាទីរបស់បុរសដែលប្រព្រឹត្តនោះ ដូច្នេះអ្នកនោះនឹងមិនអាចបន្តនៅក្នុងការប៉ះពាល់ ដោយផ្ទាល់ជាមួយនឹងអ្នកទោសបានទៀតទេ។ យោងតាមការដឹងរបស់អង្គការ លីកាដូ មិនមានការស៊ើបអង្កេតណាមួយត្រឹមត្រូវទេអំពីឧប្បត្តិហេតុនេះ ហើយឆ្មាំពន្ធនាគារនោះ ក៏មិនបានទទួលរងវិធានការដាក់វិន័យណាមួយឡើយ។

> "ស្ត្រីមានផ្ទៃពោះបួនខែម្នាក់បានរាយការណ៍ប្រាប់អង្គការ លីកាដូថា ឆ្មាំពន្ធនាគារម្នាក់បានវាយចំខ្នងខាងក្រោមរបស់គាត់ជាមួយនឹង ដំបងឈើ ហើយបានប្រាប់គាត់ថាគេវាយគាត់ "សម្រាប់ការសប្បាយ"។"

នៅពេលដែលរដ្ឋមួយដកហូតសិទ្ធិសេរីភាព អ្នកណាម្នាក់ រដ្ឋនោះក៏ត្រូវទទួលយកភារកិច្ចថែទាំដល់អ្នកទាំងនោះផងដែរ ហើយបន្ទាប់មករដ្ឋនោះត្រូវថែរក្សាសុវត្ថិភាពរបស់គាត់ និងការពារសុខុមាលភាពរបស់គាត់។ស្ថាប័នទាំងឡាយមានភារកិច្ចមួយក្នុងការការពារអ្នកជាប់ពន្ធនាគារទាំងអស់ដោយស្មើភាពគ្នា។

ទោះជាអ្នកប្រព្រឹត្តិបទល្មើសនៃការបំពាន គឺជានគរបាល ឬមន្ត្រីពន្ធនាគារ អ្នកជាប់ពន្ធនាគារដូចគ្នា ឬបុគ្គលឯទៀតក៏ដោយ នៅពេលដែលការបំពានកើតឡើងនៅក្នុងការឃុំឃាំងរបស់រដ្ឋ ក៏គឺជាការទទួលខុសត្រូវធំបំផុតរបស់រដ្ឋដើម្បីការពារ ស៊ើបអង្កេត និងដាក់ទោសអ្នកដែលបានប្រព្រឹត្ត។

សក្ខីភាពដែលអង្គការ លីកាដូ បានទទួល បង្ហាញអោយឃើញថា នៅពេលដែលមន្ត្រីរដ្ឋមិនមែនជាអ្នកប្រព្រឹត្ត ដំបូងនៃការបំពាននៅក្នុងពន្ធនាគារប្រទេសកម្ពុជា អ្នកទាំងនោះជាញឹកញាប់បានបញ្ជា ឬបានផ្តល់ការអនុញ្ញាតចំពោះការបំពាននោះ។ បើសិនជាអ្នកទាំងនោះ មិនបានចេញបញ្ជាដោយផ្ទាល់ ពួកគេជា ទូទៅបានដឹងលឺថាការបំពានបានកើតឡើង ហើយពួកគេមិនបានធ្វើសកម្មភាពដើម្បីទប់ស្កាត់នោះទេ។ ដូច្នេះអ្នកទាំងនោះជាអ្នកផ្សំគំនិត។

បើសិនសូម្បីតែមន្ត្រីរដ្ឋមិនដឹងថាការបំពានបានកើតឡើង នៅក្រោមការឃុំឃាំងរបស់ពួកគេ ដូច្នេះពួកគេគឺពិតជាបរាជ័យភារកិច្ចមួយនៃភារកិច្ចថែទាំសំខាន់បំផុតរបស់អ្នកទាំងនោះ ក្នុងការការពារអ្នកដែលនៅក្រោមការឃុំឃាំងរបស់គេ។

# អំពើហិង្សាលើកុមារមិនត្រូវបានអើពើ

ប្រហែលជាឧទាហរណ៍ដ៏ភ្ញាក់ផ្អើលបំផុត នៃភាពអសកម្ម របស់មន្ត្រីចំពោះការបំពាននៅក្នុងពន្ធនាគារ គឺទាក់ទងនិងការបំពាន លើកុមារដែលរស់នៅក្នុងពន្ធនាគារជាមួយម្តាយរបស់ពួកគេ។ នៅ ចុងខែមេសា ឆ្នាំ២០១៤ មានក្មេងចំនួន ៣៩នាក់ រស់នៅជាមួយ ម្តាយរបស់ពួកគេនៅក្នុងពន្ធនាគារចំនួន ៨ កន្លែងនៃពន្ធនាគារទាំង ឡាយដែលត្រូវបានត្រួតពិនិត្យដោយអង្គការ លីកាដូ។ ភាគច្រើន ក្មេងទាំងនោះមានអាយុក្រោម ៣ឆ្នាំ[១០]។

អង្គការ លីកាដូ បានបង្ហាញហេតុផលជាយូរណាស់មក ហើយថាប្រព័ន្ធពន្ធនាគាររបស់ប្រទេសកម្ពុជា គឺពិតជាអសមត្ថភាព ក្នុងការផ្តល់អោយកុមារនូវតម្រូវការមូលដ្ឋានសំខាន់ៗបំផុត ដែលរួម មាន ដូចជា ការសិក្សា ជីវិតគ្រួសារ ចំណីអាហារប៉ប៉នត្រឹមត្រូវ និង ការថែទាំសុខភាព។ ក៏ប៉ុន្តែលើសពីនេះ មានការពិត ដែលអាក្រក់ជាង នេះទៅទៀត ។ ប្រព័ន្ធពន្ធនាគាររបស់ប្រទេសកម្ពុជាហាក់ដូចជា អសមត្ថភាពក្នុងការពារកុមារ ពីការបំពានដ៏អាក្រក់ទៅលើរាងកាយ និងដោយពាក្យសំដី ។



កុមារ ដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារកម្ពុជា ឆ្នាំ២០១១

ថ្មីៗនេះ អង្គការ លីកាដូ បានកំពុងតែយកចិត្តទុកដាក់លើ ករណីកុមារ ដែលត្រូវបានវាយដំនៅក្នុងពន្ធនាគារ។ អាជ្ញាធរមិនបាន អន្តរាគមន៍ ហើយក៏មិនបានធ្វើសកម្មភាពណាមួយដើម្បីការពារកុមារ ទាំងនោះពីការបំពានបន្តបន្ទាប់ទៀតនោះឡើយ។

ការសម្រេចចិត្តអនុញ្ញាតអោយកុមារនៅក្រោមអាយុ ៣ ឆ្នាំ ស្នាក់នៅជាមួយម្តាយរបស់អ្នកទាំងនោះ នៅក្នុងពន្ធនាគារ គួរតែពឹង ផ្អែកទៅលើការវាយតម្លៃបុគ្គលឲ្យគ្រប់ជ្រុងជ្រោយ ហើយក្នុងគោល ការណ៍បង្ហាញផ្លូវចំបងបំផុតរបស់អ្នកទាំងនោះ ត្រូវតែផ្តល់ប្រយោជន៍ ច្រើនបំផុតដល់កុមារ[១១] ។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃ ប្រភេទ នេះ មិនត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាទេ។ កុមារអាច ត្រូវបានបញ្ជូនទៅពន្ធនាគារ ដោយគ្រាន់តែពួកគាត់មានវត្តមាននៅ ពេលចាប់ខ្លួន ហើយមធ្យោបាយផ្សេងៗដែលសមរម្យកម្រនឹងត្រូវបាន យកមក ពិចារណាណាស់។ ជាញឹកញាប់ម្តាយជាអ្នកសម្រេចចិត្ត ថា តើកូនរបស់គាត់នឹងរស់នៅជាមួយគាត់ ហើយអាជ្ញាធរកម្រចូលរួម ក្នុងការ សម្រេចចិត្តនេះ ឬ ត្រូវបានសួរពីការសម្រេចចិត្តនេះណាស់។

នីតិវិធីពន្ធនាគារ ចំពោះស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារ ប្រទេសកម្ពុជាចែងថា នៅពេលដែលកុមារស្នាក់អាស្រ័យជាមួយ និងម្តាយនៅក្នុងពន្ធនាគារ "ម្តាយមានទំនួលខុសត្រូវសម្រាប់ការថែ ទាំ និងសុវត្ថិភាពរបស់កុមារនោះ"[១២] ។ នីតិវិធីទាំងនេះ ក៏បានចែងថា នៅពេលដែលអ្នកទោស" មិនអាចផ្តល់ការថែទាំគ្រប់គ្រាន់ដល់កូន នៅក្នុងពន្ធនាគារដោយសារតែមូលហេតុណាមួយក៏ដោយ ប្រធាន ពន្ធនាគារ...ត្រូវតែរៀបចំជាមួយនិងក្រសួងពាក់ព័ន្ធ ឬសមាជិក គ្រួសារសម្រាប់ការថែទាំកុមារនៅក្រៅពន្ធនាគារ"[១៣] ។

ខណៈដែលម្តាយ គួរតែទទួលខុសត្រូវទាំងស្រុងចំពោះកូន នៅក្នុង ពន្ធនាគារអាជ្ញាធរមិនអាចច្រានចោលការទទួលខុសត្រូវទាំង ស្រុង នោះទេ។ ដូចជានៅក្នុងករណីទាំងអស់នៃការបំពានលើកុមារ នៅក្នុង ឬក្រៅពន្ធនាគារ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែអន្តរាគមន៍ ហើ យត្រូវតែអនុវត្តន៍វិធានការបន្ទាន់ ដើម្បីទប់ស្កាត់ការបំពានតទៅមុខ ទៀត។ មន្ត្រីពាក់ព័ន្ធគួរតែត្រូវបានហ្វឹកហ្វឺនមិនត្រឹមតែអំពីតម្រូវការនៃ ការលូតលាស់ និងការថែទាំសុខភាពរបស់កុមារទេ ប៉ុន្តែក៏គួរតែត្រូវ បានហ្វឹកហ្វឺនអំពីរបៀបក្នុងការពិនិត្យនិងស្គាល់ពីសញ្ញា នៃការបំពាន ហើយត្រូវអន្តរាគមន៍ដោយសមស្រប។

អង្គការ លីកាដូ ជឿថា ក្នុងករណីដែលមិនមានការវាយតម្លៃ ពេញលេញ និងជាបន្តបន្ទាប់នូវអ្វីដែលល្អបំផុតសំរាប់កុមារ ហើយជា ពិសេសក្នុងករណី ដែលមិនមានការវាយតម្លៃថាតើម្តាយអាចថែទាំ និងការពារកូនរបស់នាងបានសមរម្យដែរឬទេនៅក្នុងប្រព័ន្ធពន្ធនាគារ របស់កម្ពុជា អាជ្ញាធរក៏ត្រូវតែមានការទទួលខុសត្រូវមួយចំនួនផងដែរ សម្រាប់ការគាំពារកុមារទាំងនេះ មិនមែនត្រឹមតែនៅក្នុងករណីនៃការ សង្ស័យការបំពាននោះទេ។

នៅក្នុងន័យនេះ អាជ្ញាធរពន្ធនាគារត្រូវការការប្តេជ្ញាចិត្ត និង ការគាំទ្រទាំងស្រុងពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា (MoSAVY) ដែលជាភ្នាក់ងារដែលគួរតាទទួលខុសត្រូវក្នុង ការដឹកនាំការវាយតម្លៃនៃភាពជាអាណាព្យាបាល ដែលសមស្រប ហើយនឹងការដកចេញ និងផ្លាស់ប្តូរទីលំនៅថ្មីដោយសុវត្ថិភាពចេញពី ពន្ធនាគារ។ ប៉ុន្តែដោយអកុសល មកដល់ថ្ងៃនេះ ការតាំងចិត្ត និង ការគាំទ្រនេះ កំពុងតែមានការខ្វះខាត ដោយគួរអោយចាប់អារម្មណ៍។

[១០] ក្នុងចំណោមកុមារទាំងអស់ ៦នាក់ មានអាយុលើសពី ៣ឆ្នាំ ដែលរំលោភលើច្បាប់ពន្ធនាគារឆ្នាំ២០១១ ដែលកាត់បន្ថយដែនកំណត់អាយុរបស់កុមារពី ៦ឆ្នាំ ទៅ ៣ឆ្នាំ ក្នុងការអនុញ្ញាត អោយស្នាក់នៅក្នុងគុក។ ច្បាប់នេះ ក៏បានបដិញ្ញាតផងដែរថា កុមារដែលមានអាយុលើសពី ៣ឆ្នាំ គួរតែនៅក្រោមការទទួលខុសត្រូវរបស់ MOSAVY បើសិនជាមិនមានអណាព្យាបាលថែទាំពួក គេនៅខាងក្រៅពន្ធនាគារ។

[១១] ច្បាប់របស់ អ.ស.ប. (UN) សម្រាប់ឥរិយាបទចំពោះអ្នកទោសស្រី និងគោលការណ៍មិនផ្តល់សិទ្ធអណាព្យាបាលស្ត្រីប្រព្រឹត្តបទល្មើស (ច្បាប់បាងកក) ច្បាប់ទី៤៩ និង៥២ និងមាត្រាទី៣ (១) នៃសន្និបាទ អ.ស.ប. (UN) អំពីសិទ្ធិទទួលបានកូន

[១២] កថាខ័ណ្ឌទី៤.៦ នៃនីតិវិធីពន្ធនាគារ លេខ ៣៤, ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៣

[១៣] ដូចខាងលើកថាខ័ណ្ឌទី៤.១០

# ទារុណកម្ម និងសុខភាពផ្លូវចិត្ត

ការបារម្ភមួយ គឺរបាយការណ៍អំពីអ្នក ដែលមានបញ្ហាសុខភាពផ្លូវចិត្តអាចនៅ ក្នុងស្ថានភាពហានិភ័យ ដោយពួកគាត់អាចជាគោលដៅសម្រាប់ការបំពាននៅក្នុងពន្ធនាគារ ឬ ក្នុងការឃុំឃាំងរបស់នគរបាល។

ចាប់ពីខែមករា ឆ្នាំ២០១១ ដល់ខែធ្នូ ឆ្នាំ២០១៣ អង្គការ លីកាដូ បានអនុវត្តគម្រោងរួមគ្នាមួយជាមួយនិងអង្គការដៃគូ គឺអង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) កម្ពុជា ដែលជាអង្គការខ្មែរមួយនាំមុខនៅក្នុងវិស័យសុខភាពផ្លូវចិត្ត និងការអន្តរាគមន៍ចិត្តសង្គម។

> “អ្នកទោសម្នាក់ដែលមានជំងឺផ្លូវចិត្តត្រូវបានប្តូរពីបន្ទប់ពន្ធនាគារមួយទៅបន្ទប់ពន្ធ-នាគារមួយទៀតដែលគាត់ត្រូវបានវាយប្រហារយ៉ាងឃោរឃៅដោយអ្នកទោសដូចគ្នា។ គាត់ត្រូវបានគេវាយរហូតដល់គាត់ហូរឈាម និងបាត់បង់ស្មារតី...”
>
> បុរសម្នាក់ ដែលបានរាយការណ៍ពីការបំពាន ចន្លោះពីឆ្នាំ២០១០ ដល់ ២០១២

គោលដៅនៃគម្រោងនេះ គឺដើម្បីពង្រឹងស្ថានភាពរបស់អ្នកជាប់ពន្ធនាគារនៅក្នុង ១៩ ពន្ធនាគារក្នុងប្រទេសកម្ពុជា ដែលលំអិតទៅលើអ្នកនៅរស់ក្រោយពីទារុណកម្ម ហើយនិងដើម្បីធានាថាសិទ្ធិរបស់ពួកគេត្រូវបានគេគោរព។ គម្រោងនេះ ផ្តោតទៅលើស្ថានភាពពន្ធនាគារ សេវាផ្លូវច្បាប់ និងសុខភាព ការពង្រឹងនៃការពិគ្រោះយោបល់ និងការចែករំលែកពត៌មានរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ហើយនិងការពង្រឹងយុទ្ធនាការតស៊ូមតិទាក់ទង នឹងពន្ធនាគារ។

ក្នុងអំឡុងពេលនៃគំរោងនេះ TPO បានផ្តល់ការបណ្តុះបណ្តាលដល់អ្នកស្រាវជ្រាវពន្ធនាគារ នឹងបុគ្គលិកវេជ្ជសាស្ត្ររបស់អង្គការ លីកាដូ អំពីរបៀបក្នុងការបញ្ជាក់ភិនភាគអ្នកទោស ដែលត្រូវការការព្យាបាលសុខភាពផ្លូវចិត្ត។ ការបណ្តុះបណ្តាលនេះគ្របដណ្តប់លើស្ថានភាពផ្លូវចិត្ត អាការៈ និងការបង្ហាញអោយឃើញពីការធ្វើទារុណកម្ម។ បុគ្គលិកអង្គការ លីកាដូ ជារឿយៗបានបញ្ជូនករណីទៅអោយ TPO ដើម្បីធ្វើការវាយតម្លៃ និងការព្យាបាលគ្រប់ជ្រុងជ្រោយនៃសុខភាពផ្លូវចិត្ត ដែលក្នុងនោះរួមមានករណីនៃទារុណកម្មដែលបានចោទប្រកាន់។

អង្គការ TPO បច្ចុប្បន្នកំពុងផ្តល់សេវាព្យាបាលសុខភាពផ្លូវចិត្តដល់ពន្ធនាគារគោលដៅបួន និងផ្តល់ការធ្វើអន្តរាគមន៍ចំពោះវិបត្តិនៅតំបន់ផ្សេងទៀត។ ជាការគួរឲ្យកត់សំគាល់ថាក្នុងអំឡុងពេលនៃគម្រោងរួមគ្នានេះ TPO បានកត់ត្រាករណីមួយចំនួន នៃការបំពាន ដែលទទួលបានពីក្រុមគោលដៅតូចៗរបស់ពួកគាត់នៅក្នុងពន្ធនាគារទាំងបួននោះ។

របាយការណ៍ទាំងនេះ គឺស្របជាមួយនឹងប្រភេទនៃការចោទប្រកាន់ ដែលទទួលបានដោយអង្គការ លីកាដូ ហើយក្នុងនោះ រួមមានអ្នកជាប់ឃុំឃាំងត្រូវបានទះទាត់ និងរុញច្រាន ហើយត្រូវបានវាយជាមួយនិងវត្ថុ ដូចជាកាំភ្លើង ត្រូវបានរលោក

## ការប៉ះទង្គិចផ្លូវចិត្តពីការធ្វើទារុណកម្ម

បន្ថែមពីលើការប៉ះទង្គិចលើសុខភាពរាងកាយ TPO ក៏បានរកឃើញផលប៉ះពាល់រយៈពេលវែង បង្កឡើងដោយការបំពាន ចំពោះសុខុមាលភាពផ្លូវចិត្តរបស់អ្នកជំងឺរបស់អ្នកទាំងនោះ។

អ្នកជំងឺ TPO ក្នុងពន្ធនាគារ ដែលត្រូវបានរងទុក្ខ ឬបន្តរងទុក្ខ ឬរងការធ្វើបាប បានរាយការណ៍អំពីអាការៈដែល រួមមានការឈឺក្បាល រសាប់រសល់ បាក់ទឹកចិត្ត រំខានដំណេក លឺសំឡេង ការភ័យព្រួយខ្វាប់ខ្វួន ឆាប់ឆេវឆៅ និងឆាប់ខឹង ហើយនឹងមានប្រតិកម្ម ភ្ញាក់ផ្អើល។

អ្នកជំងឺ TPO ខ្លះដែលបានឆ្លងកាត់ការបំពានបានព្យាយាមធ្វើអត្តឃាត។ អ្នកឯទៀតបានបង្ហាញអោយឃើញគំនិតចង់ធ្វើអត្តឃាត។

ការប៉ះទង្គិចចិត្តសាស្ត្រដោយសារទារុណកម្ម និងការធ្វើបាន មិនមែនគ្រាន់តែជាការព្រួយបារម្ភតែមួយគត់នៅក្នុងករណីរបស់អ្នក ដែលធ្លាប់ឆ្លងកាត់បញ្ហាសុខភាពផ្លូវចិត្តពីមុនមកនោះទេ។ សម្រាប់អ្នកខ្លះ ការបំពានអាចអោយសញ្ញា ដែលបង្កអោយមានបញ្ហាបែបនេះ។ ស្ថានភាពមិនល្អនៃការឃុំឃាំងក្នុងប្រទេសកម្ពុជា រួមផ្សំជាមួយនឹងកង្វះខាតនៃការទាក់ទងជាមួយពិភពលោកខាងក្រៅ អាចធ្វើអោយស្ថានភាពជំងឺដែលមានរួចហើយរបស់អ្នកទាំងនោះ កាន់តែធ្ងន់ធ្ងរឡើង។

ក្រុមប្រឹក្សានីតិសម្បទាអន្តរជាតិសម្រាប់ជនរងគ្រោះដោយទារុណកម្ម (IRCT) កត់សំគាល់ថា “លទ្ធផលនៃការធ្វើទារុណកម្មអាចឈានហួសឆ្ងាយពីការឈឺចាប់ភ្លាមៗ...ជនរងគ្រោះដោយទារុណកម្ម ជាញឹកញាប់តែងតែមានអារម្មណ៍មានកំហុស និងខ្មាសអៀនដែលបង្កឡើងដោយការប្រមាថ ដែលអ្នកទាំងនោះបានទទួលបានរង។ មនុស្សច្រើននាក់មានអារម្មណ៍ថាពួកគេបានក្បត់ខ្លួនឯង ឬមិត្តរបស់ពួកគេ និងគ្រួសាររបស់គេ។ អាការៈទាំងអស់នេះ គឺជាលទ្ធផលអវិជ្ជមានធម្មតារបស់មនុស្សចំពោះអំពើឥតមនុស្សធម៌ និងមិនប្រក្រតី”[១៤] ។

នៅក្នុងប្រទេសកម្ពុជា អ្នកដែលរួចពីទារុណកម្ម កម្រនឹងការទទួលបានការគាំទ្ររយៈពេលយូរផ្នែកសំភារៈ ការព្យាបាល ចិត្តសាស្ត្រ និងសង្គម ដែលពួកគាត់អាចត្រូវការ ដើម្បីកសារជីវិតរបស់ពួកគាត់ឡើងវិញនោះណាស់។ មានសេវាកម្មឯកទេសមួយចំនួនតូចសម្រាប់អ្នកដែលរួចពីទារុណកម្ម និងដោយឡែកពីសេវាកម្មរបស់ TPO ការថែទាំសុខភាពផ្លូវចិត្តនៅក្នុងពន្ធនាគារ គឺជាក់ស្តែងមិនសូវមានទាល់តែសោះ។ ទោះជាសម្រាប់អ្នក ដែលអាចស្វែងរកសេវាកម្មប្រភេទនេះនៅខាងក្រៅពន្ធនាគារបានក៏ដោយ ក៏គុណភាពនៃការថែទាំសុខភាពផ្លូវចិត្តសាធារណៈ នៅតែមានភាពអន់ខ្សោយ ជាពិសេសនៅតំបន់ជនបទ។

អង្គការចិត្តសង្គម អន្តរវប្បធម៌
Transcultural Psychosocial Organization
Community Mental Health Programme

[១៤] http://www.irct.org/what-is-torture/effects-of-torture.aspx.

ដោយទឹកពុះនិងបារី ត្រូវបានធ្វើអោយថប់ដង្ហើមជាមួយនឹងថង់ផ្លាស្ទិច ឬ ក្រណាត់បិទភ្នែក ត្រូវបានគេយកវត្ថុស៊កចូលក្នុងទ្វារធំ ត្រូវបានគេគម្រាមសម្លាប់ រំលោភ ច្របាច់ក និងអំពើហឹង្សាលើរាងកាយផ្សេងទៀត ហើយត្រូវបានគេបង្ខំអោយអង្គុយ ឈរ ឬ លុតជង្គង់នៅក្នុងជំហរដដែលរយៈពេលច្រើនម៉ោង។ អ្នកជំងឺរបស់ TPO ខ្លះក៏បានប្តឹងផងដែរ អំពីការបង្អត់មិនអោយទទួលទានដំណេក ការបដិសេធក្នុងការផ្តល់ថ្នាំពេទ្យ និងការប្តឹងពីស្ថានភាពទាំងមូលនៃការឃុំឃាំងរបស់អ្នកទាំងនោះ។

ចំពោះលទ្ធផលរកឃើញរបស់អង្គការ លីកាដូ ភាគច្រើននៃការបំពាន ដែល បានរកឃើញដោយ TPO គឺវាត្រូវបានធ្វើឡើងនៅក្នុងការឃុំឃាំងរបស់នគរបាល។ នៅក្នុងពន្ធនាគារ ការបំពាន គឺបង្កឡើងដោយស្នាដៃទណ្ឌិតឯទៀត និងដោយស្នាដៃឆ្មាំពន្ធនាគារផងដែរ។

TPO កម្ពុជាបានបន្តគាំទ្រអ្នកទោសទាំងប្រុស និងស្រី នៅក្នុងពន្ធនាគារគោលដៅទាំងបួន។ ក្នុងនាមជាអ្នកផ្តល់ការគាំទ្រ និងការព្យាបាលផ្នែកសុខភាពផ្លូវចិត្ត និងចិត្តសង្គម អង្គការមួយនេះ មានភារកិច្ចដ៏ពិសេសពិសាលក្នុងការស្វែងរកអ្នក ដែលកំពុងឆ្លងកាត់បញ្ហាសុខភាពផ្លូវចិត្ត ហើយត្រូវបានទទួលរងការធ្វើទារុណកម្ម ឬ ការធ្វើបាប នៅក្នុងការឃុំឃាំង។ បន្ទាប់មក គ្រូពេទ្យផ្លូវចិត្តរបស់ TPO អាចវាយតម្លៃ និងផ្តល់ការព្យាបាលទៅដល់អ្នករងគ្រោះផ្លូវចិត្តដោយសារតែការបំពានបែបនេះ។

> “ខ្ញុំត្រូវបានគេធ្វើទារុណកម្មដោយគ្មានហេតុផល។ នៅពេលដែលខ្ញុំត្រូវបានគេចោទប្រកាន់ ខ្ញុំត្រូវបានគេវាយយ៉ាងសាហាវព្រៃផ្សៃរហូតដល់ខ្ញុំសន្លប់។ នៅពេលដែលគេអោយអ៊ុកស៊ីសែនខ្ញុំ ខ្ញុំដឹងខ្លួនឡើងវិញមួយរយៈ។ នៅពេលខ្ញុំព្យាយាមបកស្រាយប្រាប់ពួកគេថា ខ្ញុំមិនបានធ្វើអ្វីខុសទេ ខ្ញុំត្រូវបានគេវាយសួរចម្លើយហើយវាយរហូតដល់សម្លប់ម្តងទៀត”។
>
> បុរសម្នាក់ ដែលបានរាយការណ៍ពីការបំពាន ចន្លោះពីឆ្នាំ២០១០ ដល់ ២០១២

អ្នកទោស ដែលកំពុងឆ្លងកាត់បញ្ហាសុខភាពផ្លូវចិត្ត អាចមានការលំបាកជាពិសេសក្នុងនិយាយអំពីការបំពាន ដោយសារតែមូលហេតុមួយចំនួន រួមមាន ដូចជារបាំងផ្លូវចិត្ត និងការភ័យខ្លាចនៃការវាយដំបន្ថែមទៀត។ ទោះជាយ៉ាងក៏ដោយ ការវាយតម្លៃចិត្តសាស្ត្រត្រូវបានធ្វើឡើងដោយ TPO និងសក្ខីភាពផ្ទាល់ខ្លួនរបស់អ្នកជាប់ឃុំឃាំងមួយចំនួន មិនបានបន្សល់ទុកការមន្ទិលសង្ស័យណាមួយថាអ្នកទាំងនេះ នៅក្នុងហានិភ័យមួយដែលអាចទទួលរងការបំពាន។



ទ្វារចូលបន្ទប់ឃុំឃាំងសម្រាប់អ្នកទោសជាបុរស ក្នុងពន្ធនាគារកម្ពុជា ឆ្នាំ២០១០

# វិន័យដែលមិនមានបញ្ញត្តិ

ខណៈដែលពិតជាមាន តម្រូវការនៃប្រព័ន្ធ នៃការដាក់វិន័យ មួយនៅក្នុង គ្រ ប់ កន្លែងឃុំឃាំង បទដ្ឋានអន្តរជាតិចែងថាវិធានការ ដាក់វិន័យទាំង ឡាយ គួរតែត្រូវបានបញ្ញត្តិត្រឹមត្រូវ ដើម្បីធានាថា ការ ចោទប្រកាន់ លើការធ្វើខុសត្រូវបានដោះស្រាយដោយយុត្តិធម៌ ហើយ ដើម្បីធា នាថាការដាក់ទណ្ឌកម្ម គឺសមាមាត្រទៅនិងឧបទ្ទវហេតុដែល បានចោទ ប្រកាន់ ហើយទណ្ឌកម្មនោះត្រូវបានធ្វើឡើងប្រកបដោយ មនុស្សធម៌។

ស្របតាម បទដ្ឋានទាំងនេះ គោលការណ៍ពន្ធនាគាររបស់ ប្រទេសកម្ពុជា ឲ្យអត្ថន័យអំពើដែលបង្កអោយល្មើសវិន័យ ហើយ បានកំណត់នីតិវិធីដែលនឹងត្រូវបានអនុវត្តន៍ នៅពេលដែលទទួល បានរបាយការណ៍វិន័យ[១៥] និងដំណាក់កាលនៃការស៊ើបអង្កេត ដែល គួរអនុវត្ត ក្នុងនោះរួមមានលទ្ធភាពសម្រាប់អ្នកទោសក្នុងការប្តឹង ឧទ្ធរណ៍ទៅនឹងការសំរេចចិត្តដាក់វិន័យផងដែរ[១៦]។

ទោះជាយ៉ាងណាក៏ដោយ ក្នុងពេលអនុវត្តន៍គោលការណ៍ ទាំងនេះ គឺកម្របានត្រូវអនុវត្តន៍តាម ហើយជាញឹកញាប់អ្នកទោស មិនត្រូវបានផ្តល់ឱកាស ដើម្បីការខ្លួនពួកគាត់ពីអ្នកដែលចោទប្រកាន់ ពួកគាត់។ អង្គការ លីកាដូ ក៏បានកត់ត្រាផងដែរអំពីការប្រើប្រាស់ វិធានការដាក់ទោស ដែលលើសកំណត់ពីអ្វីដែលចាត់ទុកថាអាច ទទួលយកបានក្រោមបទដ្ឋានអន្តរជាតិ និងច្បាប់កម្ពុជា។

ប្រហែលជាសំខាន់បំផុតនៅក្នុងបរិបទកម្ពុជា បញ្ញត្តិជាបទ ដ្ឋានអប្បបរមា សម្រាប់គ្រប់គ្រងអ្នកទោស (SMR) ចែងថា មានតែ មន្ត្រីពន្ធនាគារប៉ុណ្ណោះ ដែលអាចប្រើប្រាស់អំណាចដាក់វិន័យលើអ្នក ទោសបាន[១៧]។ វិន័យនេះ គឺត្រូវបានរៀបចំឡើងក្នុងគោលដៅ ដើម្បី បញ្ឈប់រចនាសម្ព័ន្ធការដឹកនាំបន្ទប់ពន្ធនាគារ ដែលយកការដាក់ វិន័យជាគោល ដែលមាននៅក្នុងពន្ធនាគារភាគច្រើនក្នុងប្រទេស កម្ពុជា។

ដូចដែលបានកត់សំគាល់ ជាញឹកញាប់ក្រោមការបញ្ជា របស់អាជ្ញាធរពន្ធនាគារ ប្រធានបន្ទប់ និងសមាជិកនៃគណៈកម្មាធិការ គ្រប់គ្រងបន្ទប់ ជាទំលាប់បានដាក់ពិន័យអ្នកទោសដែលប្រព្រឹត្ត ល្មើសវិន័យផ្លូវការ ឬក្រៅផ្លូវការ (វិន័យមិនបានសរសេរ)។ ការវាយដំ និងការដាក់ទោសផ្សេងទៀតជារឿយៗ គឺអយុត្តិធម៌ ធ្វើឡើងភ្លាមៗ និងឃោរឃៅ ហើយអ្នកដែលអនុវត្តការដាក់ទណ្ឌកម្មបានធ្វើឡើង ដោយមិនខ្លាចពីការដាក់ទោស លើខ្លួនរបស់ពួកគេនោះទេ (និទណ្ឌភាព)។

ការប្រើប្រាស់អ្នកទោសដើម្បីវាស់ការដាក់ទណ្ឌកម្ម ឬការ ទ្រាំទ្រ នោះអាចធ្វើអោយមានការបំពានយ៉ាងលើសលុប។ ទោះជា យ៉ាងណាចំពោះប្រភេទនៃទណ្ឌកម្មជាច្រើនទៀត ដែលត្រូវបាន រាយការណ៍ដល់អង្គការ លីកាដូ ត្រូវបានអនុវត្តដោយឆ្មាំពន្ធនាគារ ហើយក៏ដូចជាប្រធានបន្ទប់ ដែលធ្វើឡើងដោយមានបញ្ហា និងខ្វះ ខាតការត្រួតពិនិត្យ។

**ការវាយដំ និងការដាក់ទោសផ្សេងទៀតជារឿយៗ គឺអយុត្តិធម៌ធ្វើឡើងភ្លាមៗ និងឃោរឃៅ ហើយអ្នកដែលអនុវត្តការដាក់ទណ្ឌកម្មបានធ្វើឡើងដោយមិនខ្លាចពីការដាក់ទោសលើខ្លួនរបស់ពួកគេនោះទេ (និទណ្ឌភាព)។**

ថ្វីបើមានការហាមឃាត់ចំពោះទណ្ឌកម្មប្រភេទបែបនេះនៅ ក្នុងបទបញ្ញត្តិកម្ពុជាក៏ដោយ ក៏អតីតអ្នកទោសបានរាយការណ៍ថា របបអហារ និងទឹករបស់ពួកគាត់ត្រូវបានគេកាត់បន្ថយ ដើម្បីដាក់ ទណ្ឌកម្ម ដែលជា "ការដាក់ទណ្ឌកម្មអយុត្តិធម៌ដែលប៉ះពាល់ដល់ សុខភាពរបស់អ្នកទោស"[១៨] ហើយត្រូវបានដាក់ទណ្ឌកម្មច្រើនជាង មួយដងសំរាប់បទល្មើសវិន័យតែមួយ។ អង្គការ លីកាដូក៏បានទទួល របាយការណ៍ផងដែរអំពីអ្នកទោសទាំងអស់គ្នា ដែលត្រូវបានដាក់ ទណ្ឌកម្មរួម ចំពោះការចោទប្រកាន់ពីបទល្មើសលើសមាជិកបន្ទប់តែ ម្នាក់។

បន្ទាប់ពីដោះលែង ក្រោយពីការដាក់ពន្ធនាគារស្ត្រីបឹងកក់ ទាំង ១៣នាក់ នៅខែមេសា ឆ្នាំ២០១២ អង្គការ លីកាដូ បានធ្វើបទ សម្ភាសលម្អិតជាមួយអ្នកទាំងនោះ។ ពួកគាត់ជាច្រើននាក់បានកត់ សម្គាល់ថា ឆ្មាំពន្ធនាគារជារឿយៗតែងតែដាក់ទណ្ឌកម្មអ្នកទោស ទាំងអស់ ដែលនៅក្នុងបន្ទប់ពន្ធនាគារតែមួយរួមគ្នា បើសិនជាស្ត្រី ទាំងអស់នៅក្នុងបន្ទប់នោះមិនបានបង្ហាញខ្លួនគ្រប់ចំនួន ដើម្បីមកធ្វើ ការក្នុងកម្មវិធីដេរប៉ាកនៅថ្ងៃដែលបានកំណត់។ការដាក់ទណ្ឌកម្មបែប នេះជាធម្មតាមាន ដូចជាការកាត់បន្ថយពេលវេលាលំហែកាយ សម្រាប់អ្នកដែលនៅក្នុងបន្ទប់តែមួយ។

ខណៈពេល ដែលគោលការណ៍ពន្ធនាគារអនុញ្ញាតអោយ ឯកសិទ្ធិរបស់អ្នកទោសត្រូវបានដក់ហូត សម្រាប់រយៈពេលមិនលើស ពីពីរសប្តាហ៍ចំពោះបទល្មើសស្រាល ហើយនិងមិនលើសពីចំនួន សរុប ៣០ថ្ងៃ[១៩] អង្គការ លីកាដូ បានទទួលសក្ខីភាពថាទណ្ឌិតត្រូវ បានបដិសេធមិនអោយមានការទាក់ទងជាមួយគ្រួសាររបស់អ្នកទាំង នោះ ហើយអ្នកមកសួរសុខទុក្ខឯទៀតរយៈពេលច្រើនខែក្នុងពេល មួយលើកៗ។

[១៥] កថាខ័ណ្ឌទី ៣.១ នៃនីតិវិធី ៩
[១៦] ដូចខាងលើ កថាខ័ណ្ឌទី ៤.១០
[១៧] SMR, វិធាន ២៨ (១) ចែងថា " មិនមានអ្នកទោសណាមួយត្រូវបានជួលក្នុងការបម្រើសេវាកម្មរបស់ស្ថាប័ន ក្នុងការដាក់វិន័យនោះទេ" នីតិវិធីពន្ធនាគាររបស់ប្រទេសកម្ពុជា លេខ ៩ ដែល បញ្ញាត្តិអំពីវិន័យរបស់អ្នកទោសក៏បានចែងផងដែរថា ក្រុមអ្នកទោសណាមួយមិនគួរត្រូវបានប្រើប្រាស់ដើម្បីដាក់វិន័យទៅលើក្រុមអ្នកទោសណាមួយទៀតឡើយ កថាខ័ណ្ឌទី ៣.២ (ច)
[១៨] កំណែទម្រង់ព្រហ្មទណ្ឌអន្តរជាតិ "ការបង្កើតការងារតាមបទដ្ឋាន: វិធានអន្តរជាតិស្តីពីការអនុវត្តល្អក្នុងពន្ធនាគារ) ឆ្នាំ ២០០១
[១៩] កថាខ័ណ្ឌទី ៤.៧ គ នៃនីតិវិធី ៩

នីតិវិធីពន្ធនាគារស្រដៀងគ្នានេះ ដែរអនុញ្ញាតអោយឃុំឃាំងអ្នកទោសនៅក្នុងបន្ទប់របស់ពួកគាត់រហូតដល់បីថ្ងៃជាការដាក់ទណ្ឌកម្ម ប៉ុន្តែវាអាចធ្វើឡើងទៅបានលុះត្រាតែពួកគាត់នៅតែមានសិទ្ធចេញទៅទីវាលខាងក្រៅ សម្រាប់រយៈពេលមួយម៉ោងក្នុងមួយថ្ងៃ[២០]។ ទោះជាយ៉ាងណាក៏ដោយ អង្គការ លីកាដូ បានទទួលរបាយការណ៍អំពីការដាក់ទណ្ឌកម្ម ដោយឃុំឃាំងអ្នកទោសនៅក្នុងបន្ទប់របស់ពួកគាត់រយៈពេលជាច្រើនសប្តាហ៍ ឬ ជាច្រើនខែ ដោយគ្មានពេលវេលានៅខាងក្រៅបន្ទប់ទាល់តែសោះ។ របាយការណ៍ខ្លះ បានបង្ហាញថាអ្នកទោសខ្លះមានបន្ទប់ដាក់ទណ្ឌកម្មជាក់លាក់ ដែលពួកគាត់ត្រូវបានឃុំឃាំងផ្តាច់ពីអ្នកទោសឯទៀតសំរាប់រយៈពេលយូរអង្វែង។

ខណៈពេលដែលអ្នកទោសប្រុសជាទម្លាប់ ត្រូវបានវាយដោយឆ្មាំពន្ធនាគារ និងត្រូវទទួលរងអំពើហិង្សា ពីអ្នកទោសជាធម្មតាមិនសូវមានការរាយការណ៍អំពីការបំពានផ្នែករាងកាយទៅលើអ្នកទោសជាស្ត្រីនោះទេ។ ទោះជាយ៉ាងណាក៏ដោយទាំងអ្នកទោសប្រុស និងស្រីបានរាយការណ៍អំពីការប្រើប្រាស់ជាទៀងទាត់នៃការដាក់ទណ្ឌកម្មមិនសូវបើកចំហ(ដោយប្រយោល) ដែលបំពានទៅលើសិទ្ធអ្នកទោស ក្នុងនោះរួមមានដូចជាការកាត់បន្ថយរបបអាហារ និងទឹក ការបដិសេធការសួរទុក្ខរបស់ក្រុមគ្រួសារ ការដាក់កំណត់ពេលវេលានៅខាងក្រៅបន្ទប់ និងការដាក់ទណ្ឌកម្មទៅលើបន្ទប់គុកទាំងមូលចំពោះបទល្មើសដែលបុគ្គលតែម្នាក់ធ្វើ។

អតីតប្រធានបន្ទប់ស្រីម្នាក់បានប្រាប់អង្គការ លីកាដូ ថាអ្នកទោសស្រី ដែលត្រូវបានគេរកឃើញថាមានទូរស័ព្ទ ឬ អ្នកដែលមានចរិកឆេវឆាវចំពោះអ្នកទោសម្នាក់ទៀតជាធម្មតាគាត់នឹងត្រូវបានដាក់ទណ្ឌកម្មអោយជាប់ឃុំឃាំង នៅក្នុងបន្ទប់របស់គាត់រយៈពេលពីមួយខែទៅបីខែ។ អ្នកទោសឯទៀតនឹងត្រូវបានដាក់ទណ្ឌកម្មដោយបញ្ឈប់ការមកសួរទុក្ខរបស់គ្រួសាររបស់អ្នកទាំងនោះ។ ទោះជាមានការចោទនូវបទល្មើសអ្វីក៏ដោយ ក៏អតីតប្រធានបន្ទប់ម្នាក់នេះបានកត់សម្គាល់ថាអ្នកដែលមានប្រាក់ជាធម្មតាពួកគេអាចបង់ប្រាក់ដើម្បីអោយរួចផុតពីការដាក់ទណ្ឌកម្ម។

ក្នុងករណីភាគច្រើន ការដាក់ទណ្ឌកម្មអាចផ្លាស់ប្តូរបានជាមួយនឹងការបង់ប្រាក់។ អ្នកទោសអាចបង់ប្រាក់ដើម្បីទទួលបានឯកសិទ្ធិ ដែលត្រូវបានផ្អាកជាបណ្តោះអាសន្នមកវិញ ឬ ដើម្បីជៀសផុតពីការបំពានផ្នែករាងកាយ។ ប្រព័ន្ធបែបនេះមុខជាជម្រុញយ៉ាងសកម្មអោយឆ្មាំពន្ធនាគារ និងប្រធានបន្ទប់បំពានទៅលើប្រព័ន្ធដាក់វិន័យគ្មានបទបញ្ញត្តិ ដើម្បីទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ខ្លួន។

## ចេតនាក្នុងការធ្វើបាប

វិធីដាក់ទណ្ឌកម្មមួយចំនួន ដែលត្រូវបានរាយការណ៍ដល់អង្គការ លីកាដូ និងដែលបញ្ជាដោយផ្ទាល់ដោយអាជ្ញាធរពន្ធនាគារ គឺជាទម្រង់នៃការធ្វើទារុណកម្មយ៉ាងច្បាស់។ អតីតអ្នកជាប់ពន្ធនាគារម្នាក់ បានពិពណ៌នាអំពីការណ៍ ដែលគាត់បានឃើញឆ្មាំពន្ធនាគារ បានបញ្ជាអ្នកជាប់ពន្ធនាគារទាញខ្លួនឯងដោយដាក់មុខចុះក្រោមលើដី នៅទីធ្លារពន្ធនាគារទៅមកៗចំនួនបីដង។ សាក្សីផ្សេងទៀតដែលជាអ្នកជាប់ពន្ធនាគារត្រូវបានបង្ខំឲ្យឈរក្រោមកំដៅថ្ងៃក្តៅខ្លាំងរាប់ម៉ោង ហើយនៅពេលនោះត្រូវបានគេឲ្យដាក់ធុងទឹកត្រជាក់ធំលើស្មាទាំងពីររបស់អ្នកទាំងនោះ អស់ពេលយ៉ាងយូរ ហើយថែមទាំងត្រូវលុតជង្គង់លើដីទៀតផង។ អ្នកទាំងនោះ តម្រូវឲ្យធ្វើបែបនោះម្តងហើយម្តងទៀតរហូតដល់ឆ្មាំពន្ធនាគារប្រាប់ពួកគេឲ្យឈប់។ ប្រសិនបើអ្នកទាំងនោះ ទម្លាក់ធុងទឹកចុះ ពួកគេនឹងត្រូវគេវាយដំ។



ប្រកចូល និងទ្វារពន្ធនាគារកម្ពុជា ឆ្នាំ២០១២

[២០] As above, para 4.7 (d)

# លក្ខខណ្ឌនៃការឃុំឃាំង

លក្ខខណ្ឌនៃការឃុំឃាំង នៅក្នុងពន្ធនាគារកម្ពុជាភាគច្រើន មានភាពអាក្រក់ អមនុស្សធម៌ និងការបន្ទាបបន្ថោក ដែលភាគច្រើន បណ្តាលមកពីភាពចង្អៀតណែនយ៉ាងខ្លាំង កង្វះអនាម័យ និងអាហារគ្រប់គ្រាន់ ការរៀបចំការទទួលទានដំណេកមានភាពទន់ខ្សោយ និងកង្វះខាតសេវាកម្មព្យាបាលដែលត្រឹមត្រូវ។អ្នកជាប់ពន្ធនាគារជាច្រើនត្រូវបានគេបដិសេធ ក្នុងការផ្តល់នូវពេលវេលាលំហែកាយគ្រប់គ្រាន់ និងជាទៀងទាត់។ ការទាក់ទងទៅពិភពខាងក្រៅ រួមទាំងការសួរសុខទុក្ខរបស់ក្រុមគ្រួសារ ហើយក៏ដូចជាការទទួលបានសិទ្ធិជាមូលដ្ឋានភាគច្រើនតែងតែត្រូវបានកម្រិត អាស្រ័យលើចំនួននៃការបង់ប្រាក់សំណូក។

## ចំនួនអ្នកទោស និងអត្រាមធ្យមនៃចំនួនអ្នកទោស ឃ្លាំមើលដោយអង្គការ លីកាដូ (ខែមីនា ឆ្នាំ២០១៤)

| ពន្ធនាគារ | ចំនួនអ្នកទោស | អត្រាមធ្យម |
|---|---|---|
| ប៉ៃលិន | ១៤៧ | ៧៣% |
| មណ្ឌលអប់រំកែប្រែទី១ | ២,៩៥១ | ១៤៤% |
| មណ្ឌលអប់រំកែប្រែទី២ | ៦១៩ | ២០៦% |
| មណ្ឌលអប់រំកែប្រែទី៣ | ១,៣៨០ | ១៧០% |
| មណ្ឌលអប់រំកែប្រែទី៤ | ២១៤ | ១០២% |
| តាខ្មៅ | ៩០១ | ២៨៧% |
| ព្រះសីហនុ | ៣៧៥ | ២៥០% |
| កំពង់ស្ពឺ | ៣៥២ | ១៩៦% |
| កំពត | ៣៦៣ | ២២៧% |
| កំពង់ឆ្នាំង | ៣៩៤ | ១២៧% |
| កំពង់ចាម | ៧១៥ | ១១៩% |
| កំពង់ធំ | ៤៣៩ | ១៤៦% |
| កោះកុង | ២៩២ | ១៩៥% |
| ពោធិ៍សាត់ | ២៤៩ | ២០៧% |
| បាត់ដំបង | ១,០៦៦ | ១៦៤% |
| បន្ទាយមានជ័យ | ៨៤៦ | ១២១% |
| សៀមរាប | ១,១០០ | ១១០% |
| ស្វាយរៀង | ៣១៦ | ១៩៧% |
| សរុប | ១២,៧១៩ | ១៥២% |

អតីតអ្នកជាប់ពន្ធនាគារជាច្រើន បានរាយការណ៍ថា អ្នកទាំងនោះ មានពេលចេញពីបន្ទប់ពន្ធនាគារតិចជាង ៣០ នាទី ហើយមួយចំនួនទៀតរាយការណ៍ថា អ្នកទាំងនោះ ត្រូវបានអនុញ្ញាតឲ្យចេញពីបន្ទប់បានតែម្តងប៉ុណ្ណោះក្នុងរយៈពេលពីរសប្តាហ៍។ អំឡុងពេលទៅមើលពន្ធនាគារបណ្តោះអាសន្ន នៅខេត្តឧត្តរមានជ័យ កាលពីខែសីហា ឆ្នាំ២០១៣ អង្គការ លីកាដូ បានកត់សម្គាល់ឃើញថា អ្នកជាប់ពន្ធនាគារភាគច្រើន ត្រូវបានចាក់សោរឲ្យនៅក្នុងបន្ទប់ ២៤ ម៉ោងក្នុងមួយថ្ងៃ ដោយក្នុងបន្ទប់នោះមានចន្លោះតែ ០,៣៥ ម៉ែត្រការេប៉ុណ្ណោះពីម្នាក់ទៅម្នាក់ទៀត។

យោងតាមការគណនារបស់អង្គការ លីកាដូ ពន្ធនាគារទាំង ១៨កន្លែង ដែលត្រូវបានសង្កេត បច្ចុប្បន្នកំពុងផ្ទុកចំនួនអ្នកទោសនូវចំនួនយ៉ាងអតិបរមាចំនួន ១៥៣% ដោយពន្ធនាគារមួយចំនួនកំពុងផ្ទុកលើសពី ២០០%។ កម្រិតនៃភាពចង្អៀតណែនទាំងនេះ គឺមិនមានលក្ខណៈដូចៗគ្នាគ្រប់ពន្ធនាគារនោះទេ ឬនៅក្នុងពន្ធនាគារនីមួយៗនោះទេ ដោយបន្ទប់ពន្ធនាគារខ្លះ ឬអគារខ្លះ មានភាពចង្អៀតណែនជាងបន្ទប់ដទៃទៀត។ ការរៀបចំការរស់នៅក្នុងបន្ទប់ពន្ធនាគារគឺតែងតែត្រូវបានកំណត់ដោយស្ថានភាពហិរញ្ញវត្ថុ និងសង្គមរបស់អ្នកជាប់ពន្ធនាគារម្នាក់ៗ។

កម្រិតនៃភាពចង្អៀតណែនរបស់ពន្ធនាគារ កាន់តែត្រូវបានធ្វើឲ្យធ្ងន់ធ្ងរឡើង ដោយការបន្តអនុវត្តការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ និងការដាក់ទោសពន្ធនាគារដែលមានរយៈពេលវែងសម្រាប់បទល្មើសតូចតាចជាច្រើន។ នៅឆ្នាំមុន នៅខណៈដែលចំនួនជាក់ស្តែងនៃអ្នក ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការបានចាប់ផ្តើមថយចុះស្របពេលមានការថយចុះ នៃចំនួនអ្នកជាប់ពន្ធនាគារទាំងអស់ភាគរយនៃចំនួនអ្នកជាប់ពន្ធនាគារ ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការទាំងអស់ នៅតែមានកម្រិតខ្ពស់ និងមិនបានបង្ហាញសញ្ញានៃការធ្លាក់ចុះទាល់តែសោះ។

យោងតាមស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធនាគារ ខែធ្នូ ឆ្នាំ ២០១២ ចំនួនអ្នកត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការជាមនុស្សពេញវ័យទាំងអស់ ដែលរួមទាំងអ្នកដែលបានកំពុងរង់ចាំសវនាការឧទ្ធរណ៍ ឬ សវនាការចុងក្រោយ[២១] មានអត្រា ៦១% នៃចំនួនអ្នកជាប់ក្នុងពន្ធនាគារទាំងអស់។ ត្រឹមខែមិនា ឆ្នាំ២០១៤ មិនទាន់មានការប្រែប្រួលលើភាគរយ នៃអ្នកត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនការនោះទេ។ គួរឲ្យកត់សម្គាល់ អត្រានៃចំនួនអ្នកដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការជាស្ត្រី គឺខ្ពស់ជាងបុរស ដោយមានអត្រា ៦៨% នៃចំនួនអ្នកជាប់ពន្ធនាគារជាស្ត្រីទាំងអស់ បច្ចុប្បន្ន ដែលកំពុងរង់ចាំសវនាការសាលដីកាសាលាឧទ្ធរណ៍ ឬ សាលក្រមចុងក្រោយ។

[២១] យោងតាមអង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកទូលាយ (Open Society Justice Initiative) “ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ” ត្រូវបានឲ្យនិយមន័យថាជាអំឡុងពេលដែលបុគ្គលម្នាក់ត្រូវបានគេដកហូតសេរីភាពរហូតដល់មានការបញ្ចប់នៃសវនាការព្រហ្មទណ្ឌ (រួមទាំងសវនាការឧទ្ធរណ៍)។ ដូចគ្នាដែរ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាពន្ធនាគារ ឬ International Centre for Prison Studies (ICPS) បានឲ្យនិយមន័យនៃអ្នកត្រូវបានឃុំខ្លួនបណ្តោះអាសន្នរបស់ពួកគេ ថាអ្នកដែលកំពុងរង់ចាំសាលដីកាចុងក្រោយ។

# ការមិនយកចិត្តទុកដាក់ក្នុងការផ្តល់សេវាពេទ្យលើផ្លូវកាយ និងផ្លូវចិត្ត

ច្បាប់កម្ពុជា មិនបានធានានូវលទ្ធភាពទទួលបានការថែទាំព្យាបាលដល់ជនសង្ស័យនៅក្នុងការឃុំខ្លួនរបស់នគរបាលនោះទេ។ ប៉ុន្តែការសម្រេចក្នុងការស្នើសុំឲ្យមានការព្យាបាល បែរជាស្ថិតក្នុងការសម្រេចពីព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលទៅវិញ។ ជាលទ្ធផល ការព្យាបាលអំឡុងពេលសួរចម្លើយ គឺជាក់ស្តែងមិនមាននោះឡើយ។

មុននឹងចូលពន្ធនាគារ គ្រប់អ្នកជាប់ពន្ធនាគារទាំងអស់ គួរតែទទួលបានការពិនិត្យសុខភាព ដែលត្រូវបានធ្វើឡើងដោយគ្រូពេទ្យ ឬមន្ត្រីពេទ្យដែលទទួលបានសិទ្ធិព្យាបាល និងបានចុះបញ្ជី។ ល ទ្ធផលនៃការពិនិត្យ រួមទាំងភស្តុតាងនៃរបួសរូបកាយ ជំងឺផ្លូវចិត្ត ឬការព្យាបាលរូបកាយ គួរតែត្រូវបានកត់ត្រាទុក[២២] ។ គ្រប់ការរងរបួសគួរតែត្រូវបានថតទុក និងរាយការណ៍ជូនប្រធានពន្ធនាគារ[២៣] ។

អ្នកជាប់ពន្ធនាគារភាគច្រើន ត្រូវបានបញ្ជូនទៅពន្ធនាគារតិចជាង ៤៨ ម៉ោងបន្ទាប់ពីត្រូវបានចាប់ខ្លួន ដែលជាការបង្ហាញពីសញ្ញានៃការធ្វើបាបលើរូបកាយនៅខណៈមានការឃុំខ្លួននៅប៉ុស្តិ៍នគរបាល ដូចជាស្នាមជាំ មុខរបួស និងស្នាមរលាកគួរតែនៅជាភស្តុតាងនៅពេលធ្វើការពិនិត្យ។ ទោះបីជាប្រធានពន្ធនាគារមួយចំនួនបានប្រាប់អង្គការលីកាដូថា អ្នកទាំងនោះ បានដឹងអំពីអ្នកជាប់ពន្ធនាគារ ដែលបានមកដល់ពន្ធនាគារទាំងនោះ ត្រូវការការព្យាបាលដោយសារមានការបំពានលើរាងកាយពីសំណាក់នគរបាលក៏ដោយ ក៏ប៉ុន្តែបុគ្គលិកពេទ្យជាទូទៅតែងតែមានភាពខ្វះខាតផ្នែកជំនាញ ភាពឯករាជ្យ និងសិទ្ធិក្នុងការពិនិត្យ កត់ត្រា និងរាយការណ៍ឲ្យបានត្រឹមត្រូវអំពីសញ្ញានៃការរំលោភបំពានពីអាជ្ញាធររដ្ឋទាំងនោះ។

អ្នកទាំងនោះ ដែលបានទទួលវគ្គបណ្តុះបណ្តាលត្រឹមត្រូវ និងទទួលបានសិទ្ធិព្យាបាលហាក់ដូចជាមិនមានជំនាញ ដែលតម្រូវចំពោះរោគសញ្ញានានានៃការធ្វើទារុណកម្ម។ ដូចនេះ អ្នកទាំងនោះ ក៏ហាក់ដូចជាមិនមានបទពិសោធន៍ក្នុងការយល់ដឹងពីផលប៉ះពាល់សុខភាពផ្លូវចិត្តនៃការរំលោភបំពានផងដែរ។

នេះហាក់ដូចជារោគសញ្ញាផ្លូវកាយ និងផ្លូវចិត្តនៃការធ្វើ ទារុណកម្ម ហើយនឹងការធ្វើបាបដទៃទៀត មិនត្រូវបានរកឃើញ មិនត្រូវបានរាយការណ៍ ឬ បោះចោល នៅ



បន្ទប់ព្យាបាលក្នុងពន្ធនាគារកម្ពុជា ឆ្នាំ២០១០

[២២] មាត្រា ១៩ និង២៤ នៃច្បាប់ស្តីពីពន្ធនាគារ
[២៣] ចំនុច ៣.៣ នៃនីតិវិធីនៃការចូលក្នុងពន្ធនាគារ

## ការស្លាប់អ្នកជាប់ពន្ធនាគារ ដោយមិនដឹងពីពេលវេលា និង មិនគួរស្លាប់

អង្គការ លីកាដូ បានទទួលត្រឹមតែព័ត៌មានដំបូងអំពីមូលហេតុនៃការស្លាប់របស់អ្នកជាប់ពន្ធនាគារ និងពេលខ្លះ មិនបានទទួលព័ត៌មានទាល់តែសោះ។ ប៉ុន្តែក្នុងករណីខ្លះ អង្គការ លីកាដូ ជឿជាក់ថាការបដិសេធយ៉ាងច្បាស់ និងបែបពងើយកន្តើយ ចំពោះការថែទាំសុខភាពឲ្យបានទាន់ពេលវេលា និងត្រឹមត្រូវជាមូលហេតុបណ្តាលឲ្យមានការស្លាប់អ្នកជាប់ពន្ធនាគារដែលមិនគួរស្លាប់។

អ្នកដែលមានបញ្ហាសុខភាពធ្ងន់ធ្ងរ តែងតែត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យមិនទាន់ពេលវេលា ព្រោះរោគសញ្ញារបស់អ្នកទាំងនោះមិនត្រូវបានដឹង ឬការធ្វើការពិនិត្យខុស ឬព្យាបាលខុស។ អង្គការ លីកាដូ មានការព្រួយបារម្ភអំពីអត្រាខ្ពស់នៃការស្លាប់ក្នុងចំណោមអ្នកជាប់ពន្ធនាគារវ័យក្មេង ដែលត្រូវបានគេនិយាយថាមិនមានបញ្ហាសុខភាពទាល់តែសោះនៅមុនពេលចូលក្នុងពន្ធនាគារ។

ចន្លោះខែមករា ឆ្នាំ២០១២ ដល់ខែកុម្ភៈ ឆ្នាំ២០១៤ អង្គការ លីកាដូ អាចទទួលបានព័ត៌មានលំអិតជាមូលដ្ឋាននៃស្ថានភាពជុំវិញការស្លាប់របស់អ្នកជាប់ពន្ធនាគារចំនួន ៥០នាក់។ ក្នុងចំណោមអ្នកទាំងនោះ អ្នកជាប់ពន្ធនាគារចំនួន ១៩នាក់ មានអាយុក្រោម ៣៥ឆ្នាំ នៅពេលដែលអ្នកទាំងនោះស្លាប់ ហើយភាគច្រើននៃអ្នកទាំងនោះ ត្រូវបានគេរាយការណ៍ថាមានសុខភាពល្អ នៅមុនពេលអ្នកទាំងនោះចូលក្នុងពន្ធនាគារ។ យោងតាមព័ត៌មានរបស់អង្គការ លីកាដូ អ្នកជាប់ពន្ធនាគារម្នាក់ឈ្មោះ ផន (មិនមែនឈ្មោះពិត) ដែលមានអាយុ ១៩ឆ្នាំ ត្រូវបានបញ្ជូនពីពន្ធនាគារទៅកាន់មន្ទីរពេទ្យក្នុងរយៈ៨ថ្ងៃបន្ទាប់ពី គាត់បានជូនដំណឹងដំបូងអំពីភាពស្ពឹកដៃជើងរបស់គាត់។ ផន ពីដំបូងត្រូវបានគេផ្តល់ថ្នាំដោយមន្ត្រីពេទ្យពន្ធនាគារ ប៉ុន្តែថ្នាំនេះមិនបានជួយសម្រាលស្ថានភាពជំងឺរបស់គាត់ នោះទេ។ បន្ទាប់មក ផន ត្រូវបានគេឃុំនៅក្នុងបន្ទប់ពន្ធនាគារដដែលអស់រយៈពេល ៨ថ្ងៃ ដោយមិនទទួលបានការព្យាបាលសុខភាពអ្វីទាំងអស់។ រហូតដល់ពេលដែលផនបានជូនដំណឹងអំពីការឈឺចាប់បេះដូងនៅ ៨ថ្ងៃក្រោយ ទើប ផន ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរពេទ្យ ជាកន្លែងដែលគាត់បានទទួលមរណភាពនៅថ្ងៃបន្ទាប់។ មន្ត្រីបានកត់ត្រាថា ផន បានស្លាប់ដោយសារជំងឺបេះដូង។ផនបានទទួលទោសលើសពីពាក់កណ្តាលនៃទោសរយៈពេល ១៧ ខែរបស់គាត់រួចទៅហើយ។

ពេលដែលជនរងគ្រោះកំពុងស្ថិតនៅក្នុងការឃុំខ្លួន។ អ្នកដែលត្រូវបានដោះលែងហាក់ ដូចជាមិនបានទទួលការកត់ត្រាទុកត្រឹមត្រូវអំពីរោគសញ្ញារបស់អ្នកទាំងនោះទេ ទោះជាប្រសិនបើអ្នកទាំងនោះ ទៅជួបអ្នកជំនាញផ្នែកសុខភាពក៏ដោយ ដោយសារកង្វះខាតអ្នកជំនាញទៅលើការប៉ះពាល់ផ្នែកផ្លូវកាយ និងផ្លូវចិត្តនៃការធ្វើទារុណកម្មជាទូទៅក្នុងចំណោមអ្នកជំនាញផ្នែកសុខភាពទាំងអស់ក្នុងប្រទេស។

មិនត្រឹមតែអ្នកដែលបានរងគ្រោះ ដោយការរំលោភបំពាននៅពេលមានការឃុំខ្លួនរបស់នគរបាលប៉ុណ្ណោះទេ ដែលទទួលផលប៉ះពាល់ពីប្រព័ន្ធវេជ្ជសាស្ត្ររបស់ពន្ធនាគារ អ្នកជាប់ពន្ធនាគាជាច្រើនដែលត្រូវការជំនួយផ្នែកវេជ្ជសាស្ត្រជាបន្ទាន់ ឬ ជាទៀងទាត់ ដែលរួមទាំងអ្នកដែលបានរងការរំលោភបំពាននៅក្នុងពន្ធនាគារស្រាប់ ក៏មិនទទួលការព្យាបាលទាន់ពេល និងត្រឹមត្រូវដែរ ដោយសារសេវាកម្ម និងឱសថមិនគ្រប់គ្រាន់ ហើយនិងប្រព័ន្ធដែលពុករលួយយ៉ាងខ្លាំងដែលជ្រាបចូលក្នុងសេវាកម្មព្យាបាលក្នុងពន្ធនាគារ។

នៅខណៈដែលពន្ធនាគារជាច្រើន មានមន្ត្រីពេទ្យយ៉ាងតិចម្នាក់ប្រចាំការ មន្ត្រីពេទ្យតែងតែមិនបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ ឬខ្វះសមត្ថភាពព្យាបាល។ លើសពីនេះ បន្ទប់ពេទ្យក្នុងពន្ធនាគារតែងតែខ្វះឱសថ និងឧបករណ៍ពេទ្យសម្រាប់ព្យាបាលសូម្បីតែលើជំងឺតូចតាចក៏ដោយ។

ពីព្រោះមន្ត្រីពេទ្យក្នុងពន្ធនាគារមានបទពិសោធន៍ នៅមានកម្រិត ឬ មិនមានទាល់តែសោះនៅក្នុងការថែទាំផ្នែកផ្លូវចិត្ត អ្នកជាប់ពន្ធនាគារទាំងនោះ ដែលមានបញ្ហាផ្លូវចិត្ត ត្រឹមតែបានទទួលការគាំទ្រ ឬ ព្យាបាលដែលអ្នកទាំងនោះត្រូវការ ប្រសិនបើអ្នកទាំងនោះ អាចទទួលបានសេវាកម្មពីអង្គការមិនមែនរដ្ឋាភិបាល ដែលមានជំនាញលើបញ្ហាសុខភាពផ្លូវចិត្ត ដូចជាអង្គការ TPO ជាដើម។

លើសពីនេះ អ្នកជាប់ពន្ធនាគារ តែងតែរាយការណ៍មកអង្គការ លីកាដូ ថាការព្យាបាល និងឱសថ គឺត្រូវបានផ្តល់ឲ្យតែអ្នកជាប់ពន្ធនាគារណាដែលអាចបង់ប្រាក់ ឬអ្នកដែលមានទំនាក់ទំនងល្អជាមួយអាជ្ញាធរពន្ធនាគារប៉ុណ្ណោះ។

យោងតាមបទដ្ឋានអប្បបរមា សម្រាប់គ្រប់គ្រងអ្នកទោស (SMR) អ្នកជាប់ពន្ធនាគារណាដែលទទួលរងប្រភេទនៃទណ្ឌកម្មជាក់លាក់ណាមួយ រួមទាំងការឃុំឃាំងបិទជិត ត្រូវតែទទួលការពិនិត្យជារៀងរាល់ថ្ងៃដោយមន្ត្រីពេទ្យ ដែលជាអ្នកគួរតែផ្តល់យោបល់ដល់ប្រធានពន្ធនាគារ ថាតើទណ្ឌកម្មគួរតែត្រូវបានបញ្ឈប់ដោយមូលហេតុសុខភាពផ្លូវកាយ ឬ ផ្លូវចិត្ត ឬយ៉ាងណា។

នៅក្នុងពន្ធនាគារកម្ពុជា សកម្មភាពខាងលើនេះ កម្រនឹងកើតឡើងណាស់ មួយផ្នែកដោយសារកង្វះខាតឆន្ទៈ និងចំនួនបុគ្គលិកពេទ្យនៅមានកម្រិត
នៅក្នុងពន្ធនាគារនីមួយៗ ហើយក៏ថែមទាំងដោយសារទណ្ឌកម្មក្នុងពន្ធនាគារជាច្រើនមិនមានកំនត់ក្នុងបទបញ្ជាត្រឹមត្រូវជាពិសេសទណ្ឌកម្ម ដែលប្រព្រឹត្តដោយអ្នកជាប់ពន្ធនាគារ។

ក៏ដូចគ្នាដែរ គ្រប់អ្នកជាប់ពន្ធនាគារទាំងអស់គួរតែទទួលបានការពិនិត្យផ្នែកវេជ្ជសាស្ត្រ ដើម្បីកំណត់ពីស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកទាំងនោះ មុននឹងតម្រូវឲ្យទទួលការងារក្នុងពន្ធនាគារណាមួយ ។ ការពិនិត្យទាំងនេះ មិនមាននៅក្នុងពន្ធនាគារកម្ពុជានោះទេ។ ផ្ទុយទៅវិញ អ្នកជាប់ពន្ធនាគារជាច្រើន តែងតែត្រូវបានបង្ខំឲ្យធ្វើការ ទោះបីជាអ្នកទាំងនោះមានជំងឺយ៉ាងច្បាស់ក៏ដោយ ហើយពេលខ្លះ ត្រូវទទួលរងទណ្ឌកម្មប្រសិនបើអ្នកទាំងនោះបដិសេធ។

# កង្វះខាតការដាក់ទោស និងការកែតម្រូវឡើងវិញ

អង្គការ លីកាដូ មិនបានដឹងថាតើមានការដាក់ទោស ដោយជោគជ័យពីសំណាក់មន្ត្រីអនុវត្តច្បាប់ សម្រាប់បទល្មើសដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្មនាពេល ប៉ុន្មានឆ្នាំថ្មីៗនេះ[២៦] ឬយ៉ាងណានោះទេ ហើយចំនួននៃបណ្តឹង និងការស៊ើបអង្កេតរដ្ឋបាលនៅក្នុងពន្ធនាគារ ក៏មានចំនួនទាប។

មានហេតុផលជាច្រើនសម្រាប់ហេតុការណ៍នេះ។ ជាចំនុចសំខាន់ គឺមិនមានស្ថាប័នឯករាជ្យដែលមានតួនាទីទទួល និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងនគរបាល និងមន្ត្រីអនុវត្តច្បាប់ផ្សេងទៀតនោះទេ។

នៅខណៈដែលច្បាប់ពន្ធនាគារកម្ពុជា បញ្ញត្តឲ្យមានសិទ្ធិរបស់អ្នកជាប់ពន្ធនាគារទាំងអស់ក្នុងការដាក់ពាក្យបណ្តឹង អំពីអំពើរំលោភបំពាន[២៧] អ្នកដែលព្យាយាមដាក់ពាក្យបណ្តឹងនៅក្នុងពន្ធនាគារមានការភ័យខ្លាច ថាអ្នកទាំងនោះ នឹងជាមុខសញ្ញាក្នុងការរំលោភបំពានថែមទៀតនៅថ្ងៃក្រោយ។ ការភ័យខ្លាចនេះ បន្តមាននៅក្នុងពន្ធនាគារ ដូចដែលត្រូវបានបញ្ជាក់ដោយអ្នកជាប់ពន្ធនាគារមួយចំនួន បានទទួលនូវការគម្រាមកំហែង ឬការរំលោភបំពានពីឆ្មាំពន្ធនាគារ ឬអ្នកជាប់ពន្ធនាគារផ្សេងទៀត បន្ទាប់ពីអ្នកទាំងនោះបានធ្វើការប្តឹង។

លើសពីនេះទៅទៀត មិនមានវិធានការណ៍ណាមួយត្រូវបានធ្វើឡើងសម្រាប់ការពារអ្នក ដែលចង់ដាក់ពាក្យបណ្តឹងនោះឡើយ។ ការលាក់បាំងឈ្មោះ គឺហាក់ដូចជាមិនត្រូវបានធានា ហើយអាជ្ញាធរជាច្រើន ក៏មិនត្រូវបានបំពាក់បំប៉នក្នុងការធានានូវសុវត្ថិភាពជាបន្តបន្ទាប់របស់អ្នកដាក់ពាក្យបណ្តឹងផងដែរ។ ជាឧទាហរណ៍ អង្គការ លីកាដូ បានសម្ភាសន៍អតីតអ្នកជាប់ពន្ធនាគារមួយចំនួន ដែលនៅតែត្រូវបានដាក់នៅក្នុងបន្ទប់ពន្ធនាគារដដែល ជាមួយអ្នកដែលរំលោភបំពានលើអ្នកទាំងនោះ បន្ទាប់ពីមានការដាក់ពាក្យបណ្តឹង។

[២៤] SMR rule 32 (3)
[២៥] Id. Rule 72 (2).
[២៦] យោងតាមក្រមព្រហ្មទណ្ឌកម្ពុជា ការធ្វើទារុណកម្ម និងសកម្មភាពឃោឃៅផ្សេងទៀត នឹងត្រូវទទួលទោសជាប់ពន្ធនាគាររហូតដល់ ២០ឆ្នាំ
[២៧] មាត្រា ២៨ នៃច្បាប់ស្តីពីពន្ធនាគារ

អ្នកជាប់ពន្ធនាគារមួយចំនួនតូចថ្មីៗ នឹងត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងការរាយការណ៍អំពីការធ្វើទារុណកម្ម ទៅកាន់មន្ត្រីពន្ធនាគារ ឬនគរបាល។ គ្រោះថ្នាក់ធ្ងន់ធ្ងរអាចកើតឡើងច្រើនជាផល ប្រយោជន៍នៃការដាក់ពាក្យបណ្ដឹង។

អ្នកជាប់ពន្ធនាគារមួយចំនួនតូចថ្មីៗ នឹងត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងការរាយការណ៍អំពីការធ្វើទារុណកម្ម ទៅកាន់មន្ត្រីពន្ធនាគារ ឬនគរបាល។ គ្រោះថ្នាក់ធ្ងន់ធ្ងរអាចកើតឡើងច្រើនជាផលប្រយោជន៍នៃការដាក់ពាក្យបណ្ដឹង។

ការភ័យខ្លាចការធ្វើបាបវិញ គឺមិនត្រឹមតែជាឧបសគ្គក្នុងការធ្វើបណ្ដឹងផ្លូវការ សម្រាប់អ្នកដែលនៅតែត្រូវបានឃុំខ្លួនប៉ុណ្ណោះទេ។ ហើយទោះបីសម្រាប់អ្នកដែលរៀបចំបណ្ដឹងរដ្ឋបាល មិនមានវិធានការណ៍ណាមួយ ត្រូវបានដាក់ដើម្បីធានាឲ្យមានការពិនិត្យដោយត្រឹមត្រូវ និងអព្យាក្រិត្យ ហើយប្រព័ន្ធពន្ធនាគារត្រូវបានខូចខាតដោយអំពើពុករលួយទៀតផង។

ប្រសិនបើអ្នកទាំងនោះ យល់ដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការធ្វើបែបនោះ នោះអ្នកជាប់ពន្ធនាគារមួយចំនួននឹងមានអារម្មណ៍សុវត្ថិភាពជាង និងមានឆន្ទៈច្រើនជាង ក្នុងការដាក់ពាក្យបណ្ដឹងទៅតុលាការ នៅពេលអ្នកទាំងនោះត្រូវបានដោះលែងពីពន្ធនាគារ ឬការឃុំឃាំងរបស់នគរបាល។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏រដ្ឋមិនបានផ្ដល់នូវទម្រង់នៃការការពារណាមួយដល់ជនរងគ្រោះ និងសាក្សីនោះឡើយ។

លើសពីនេះទៅទៀត អ្នកដែលចង់រាយការណ៍អំពីការរំលោភបំពាន មិនមានអ្នកតំណាងផ្លូវច្បាប់គ្រប់គ្រាន់នោះទេ។ មានភាពខ្វះខាតខ្លាំងផ្នែកជំនួយមេធាវីនៅក្នុងប្រទេសកម្ពុជា[២៨] ហើយមេធាវីឯកជនតែងតែផ្ដល់សេវាកម្មដែលមានតម្លៃថ្លៃ និងមិនអាចទុកចិត្តបាន។ ការស៊ើបអង្កេតណាមួយ ហាក់ដូចជាមិនភាពឆាប់រហ័ស ឬមិនអព្យាក្រិត្យ។ ប្រព័ន្ធតុលាការកម្ពុជា គឺពោពេញដោយអំពើពុករលួយយ៉ាងជាក់ស្ដែង និងងាយទទួលឥទ្ធិពលពីការអន្តាគមន៍ផ្នែកនយោបាយ។

អ្នកដែលអាច និងមានឆន្ទៈដាក់បណ្ដឹងឲ្យដំណើរការ គឺនឹងជួបនឹងការព្រងើយកន្តើយ ឬ ការតបតពីអាជ្ញាធរស៊ើបអង្កេត ហើយនឹងទោះបីជារបាយការណ៍ ត្រូវបានធ្វើការស៊ើបអង្កេតយ៉ាងម៉ត់ចត់ និងត្រឹមត្រូវក៏ដោយ ក៏មានលទ្ធភាពតិចតួចណាស់សម្រាប់អ្នកដាក់ពាក្យបណ្ដឹង។

មិនមានប្រព័ន្ធទូលំទូលាយនៃការផ្ដល់សំណង ឬការស្ដារនីតិសម្បទាឡើងវិញដល់ជនរងគ្រោះ នៃការធ្វើទារុណកម្មនៅក្នុងប្រទេសកម្ពុជានោះទេ ហេតុដូចនេះហើយបានជាមានពាក្យបណ្ដឹងតិចតួចដែលត្រូវបានធ្វើឡើង ត្រូវបានដោះស្រាយដោយការរៀបចំក្រៅផ្លូវការជាមួយអ្នកប្រព្រឹត្តិអំពើល្មើស ដើម្បីឲ្យមានការដកពាក្យបណ្ដឹង។ អង្គការ លីកាដូ មិនបានដឹងនូវករណីថ្មីៗណាមួយ ដែលសំណងសម្រាប់ការធ្វើទារុណកម្ម ឬការធ្វើបាបដោយភ្នាក់ងាររដ្ឋត្រូវបានផ្ដល់ឲ្យតាមរយៈតុលាការនោះទេ។

ដោយផ្អែកលើអំណះអំណាងខាងលើ គឺមិនមានការភ្ញាក់ផ្អើលនោះទេ ដែលមានជនរងគ្រោះតិចតួច មានឆន្ទៈនឹងរាយការណ៍អំពីការធ្វើទារុណកម្ម និងការធ្វើបាបផ្សេងៗ និងអ្នកដែលមិនមានសង្ឃឹមតិចតួចថាអ្វីៗនឹងបានតាមពាក្យបណ្ដឹងរបស់អ្នកទាំងនោះ។ នៅខណៈនេះ អ្នកដែលទទួលខុសត្រូវក្នុងការធ្វើទារុណកម្ម និងសកម្មភាពធ្វើបាបផ្សេងទៀត នឹងនៅតែមិនត្រូវបានទទួលទណ្ឌកម្ម និងនៅតែធ្វើសកម្មភាពអាក្រក់របស់អ្នកទាំងនោះ ម្ដងហើយម្ដងទៀត។

## គណៈកម្មាធិការអន្តរក្រសួង(មិនឯករាជ្យ និងមិនមានប្រសិទ្ធិភាព)

យោងតាមមាត្រា ១៧ នៃពិធីសារបន្ថែមនៃអនុសញ្ញាទប់ស្កាត់ទារុណកម្ម (OPCAT) កម្ពុជាគួរតែបង្កើត យន្តការបង្ការថ្នាក់ជាតិ (NPM) ឬ (NPMs) ត្រឹមឆ្នាំ២០០៨ គឺមួយឆ្នាំបន្ទាប់ពីផ្ដល់សច្ចានុម័ត។

ប៉ុន្តែ នៅក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានចេញនូវអនុក្រឹត្យស្ដីពីការបង្កើតនូវគណៈកម្មាធិការអន្តរក្រសួងថ្មីមួយ ដែលមានសមាសភាព ជាអ្នកតំណាងពីក្រសួងនានារបស់រាជរដ្ឋាភិបាលទៅវិញ។

នៅខណៈដែលយន្តការបង្ការថ្នាក់ជាតិ (NPMs) អាចមានទម្រង់ផ្សេងៗគ្នា ប៉ុន្តែត្រូវតែស្របតាមល័ក្ខខ័ណ្ឌជាក់លាក់មួយចំនួនជាអប្បបរមារបស់ OPCAT។ សំខាន់បំផុតយន្តការនេះ ត្រូវតែមិនស្ថិតនៅក្រោមឥទ្ធិពលរបស់រាជរដ្ឋាភិបាលនោះទេ។ ក្នុងចំណោមល័ក្ខខ័ណ្ឌតម្រូវផ្សេងទៀត យន្តការនេះ ត្រូវតែមានសមត្ថភាពធ្វើការដោយឯករាជ្យ ដោយមិនមានការអន្តរាគមពីអាជ្ញាធររដ្ឋនោះទេ ហើយសមាជិករបស់យន្តការនេះ គួរតែជាអ្នកជំនាញមានសមត្ថភាពគ្រប់គ្រាន់ និងឯករាជ្យ។ យន្តការនេះ ត្រូវតែមានស្វ័យភាពផ្នែកថវិការ មានលទ្ធភាពធ្វើការព្រងាងថវិកា និងប្រើប្រាស់ធនធានដោយសេរីពីការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល។

សមាសភាពរបស់យន្តការបង្ការ ថ្នាក់ជាតិបណ្ដោះអាសន្នរបស់កម្ពុជា មិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវទាំងនេះ ឬល័ក្ខខ័ណ្ឌចំបងៗបំផុតនោះទេ។ ស្ថាប័ននេះ មានសមាសភាពមកពីភ្នាក់ងារផ្សេងៗរបស់រាជរដ្ឋាភិបាលរួមមានក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយនិងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ គណៈកម្មាធិការនេះ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្ដម ស ខេង។

គណៈកម្មាធិការនេះ មិនត្រឹមតែមិនបានបំពេញនូវល័ក្ខខ័ណ្ឌមូលដ្ឋានឯករាជ្យប៉ុណ្ណោះទេ ហើយថែមទាំងធ្វើការងារមិនមាន

[២៨] ការស្រាវជ្រាវថ្មីៗរបស់ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បង្ហាញថាជំនួយផ្នែកមេធាវី គឺមានតែ ១១៩ ប៉ុណ្ណោះនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០១០ ហើយចាប់តាំងពីនោះមកចំនួននេះបានធ្លាក់ចុះមកត្រឹម ៧៦។ នៅតាមខេត្តមួយចំនួន មិនមានជំនួយផ្នែកមេធាវីទាល់តែសោះ។

[២៩] http://www.apt.ch/en/news_on_prevention/cambodia-towards-an-independent-npm/#.U4bpr5SSys9.

ប្រសិទ្ធិភាពថែមទៀតផង។ ស្ថាប័ននេះ បានធ្វើការតិចតួចបំផុតទៅលើការត្រួតពិនិត្យ រាយការណ៍ ឬ ស៊ើបអង្កេតតាមពាក្យបណ្តឹងជាក់ស្តែង។ លើសពីនេះ សិក្ខាសាលានៅខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតយន្តការបង្ការថ្នាក់ជាតិ (NPM) មួយ សមាជិករបស់គណកម្មាធិការនេះ មិនអាចបង្ហាញពីលទ្ធផលរបស់ខ្លួនទាន់ពេលវេលា ផ្ទុយទៅវិញបែរជាត្រឹមតែបង្ហាញពីកង្វះធនធាន ដែលមានសម្រាប់អ្នកទាំងនោះទៅវិញ។

អនុគណកម្មាធិការរបស់អង្គការសហប្រជាជាតិ ស្តីពីការបង្ការការធ្វើទារុណកម្ម បានមកទស្សនកិច្ចនៅកម្ពុជាចំនួនពីរដងចាប់តាំងពីកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃអនុសញ្ញាទប់ស្កាត់ទារុណកម្ម។ នៅពេលទស្សនកិច្ចលើកទៅមួយនៅខែធ្នូ ឆ្នាំ២០០៩ អនុគណកម្មាធិការនេះ បានចេញនូវរបាយការណ៍ និងអនុសាសន៍សម្ងាត់ជាច្រើន ជូនទៅរាជរដ្ឋាភិបាលកម្ពុជា។ បន្ទាប់ពីមិនទទួលបានការឆ្លើយតបទៅនឹងរបាយការណ៍នេះ អនុគណៈកម្មាធិការបានត្រឡប់មកធ្វើទស្សនកិច្ចម្តងទៀតនៅខែធ្នូ ឆ្នាំ២០១៣ ដើម្បីពិភាក្សាអំពីការអនុវត្តអនុសាសន៍កាលពីឆ្នាំ២០០៩ ហើយនិងការបង្កើតយន្តការបង្ការថ្នាក់ជាតិឯករាជ្យមួយ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (UN-OHCHR Cambodia) ដំបូងបានរៀបចំសិក្ខាសាលាមួយ ស្តីពីការបង្កើតយន្តការបង្ការថ្នាក់ជាតិឯករាជ្យ មួយកាលពីខែវិច្ឆិកា ឆ្នាំ២០១១ អំឡុងពេលអាជ្ញាធរបានបង្ហាញឆន្ទៈក្នុងការធ្វើការពង្រាងច្បាប់ស្តីពីយន្តការបង្ការថ្នាក់ជាតិថ្មីមួយ។ ផ្អែកលើសិក្ខាសាលានេះ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានផ្តល់អំណាចដល់សមាគមសម្រាប់ការបង្ការការធ្វើទារុណកម្ម (APT) ដើម្បីបង្កើតនូវការវិភាគអំពីការអនុវត្តល្អ និងមេរៀនដែលបានរៀនពីរដ្ឋផ្សេងៗទៀត។ ការសិក្សានេះ ត្រូវបានបង្ហាញនៅក្នុងសិក្ខាសាលាទីពីរ ស្តីពីការបង្កើតយន្តការបង្ការថ្នាក់ជាតិមួយ នៅរាជធានីភ្នំពេញ អំឡុងខែធ្នូ ឆ្នាំ២០១៣។

ដោយមានការកត់សម្គាល់ពីសមាគមនេះ នៅខណៈដែលគ្រប់អ្នកចូលរួមទាំងអស់ក្នុងសិក្ខាសាលា បានយល់ព្រមលើតម្រូវការសម្រាប់ប្រទេសកម្ពុជា ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញា OPCAT អានុសាសន៍មួយចំនួន ដែលត្រូវបានធ្វើឡើងនៅពេលធ្វើសេចក្តីបញ្ចប់នៃសិក្ខាសាលា ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានភាពផ្ទុយគ្នាៈ "យើងត្រូវតែក្រឡេកមើលនូវអ្វីដែលបានសម្រេចលទ្ធផលកន្លងមក ហើយអ្វីដែលនៅសល់ដើម្បីបំពេញនៅក្នុងការបង្ការការធ្វើទារុណកម្ម...យើងនឹងបន្តព្យាយាម ប៉ុន្តែអ្វីដែលយើងបានសម្រេចលទ្ធផលកន្លងមក គឺមានភាពវិជ្ជមាន"។

ផ្ទុយពីនេះ លោក Malcolm Evans ប្រធានអនុគណកម្មាធិការអង្គការសហប្រជាជាតិស្តីពីការបង្ការការធ្វើទារុណកម្ម បានកត់សម្គាល់ឃើញនូវកង្វះការវិវឌ្ឍទៅមុខឲ្យទាន់ពេលវេលា "កម្ពុជាតម្រូវមានពេលវេលាជាច្រើនឆ្នាំក្នុងការទទួលបានបទពិសោធន៍នូវអ្វី ដែលត្រូវការ ហើយពេលវេលាបានមកដល់ហើយសម្រាប់ប្រទេសនេះ ក្នុងការបំពេញការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ខ្លួន ក្នុងការបង្កើតនូវយន្តការបង្ការថ្នាក់ជាតិឯករាជ្យមួយ...នេះ គឺជាជំហានដ៏សំខាន់មួយនៅលើផ្លូវឆ្ពោះទៅកាន់ការបង្ការការធ្វើទារុណកម្ម និងការធ្វើបាបនៅអំឡុងពេលឃុំខ្លួន"។

ចាប់តាំងពីសិក្ខាសាលាខែធ្នូ ឆ្នាំ២០១៣ មិនទាន់មានការវិវឌ្ឍណាមួយត្រូវបានធ្វើឡើងឆ្ពោះ ទៅការបង្កើតយន្តការបង្ការថ្នាក់ជាតិមួយនោះទេ។


អ្នកទោសជាស្ត្រីក្នុងបន្ទប់ឃុំឃាំងរបស់ពន្ធនាគារកម្ពុជា ឆ្នាំ២០១០



អ្នកទោសជាបុរសក្នុងបន្ទប់ឃុំឃាំងរបស់ពន្ធនាគារកម្ពុជា ឆ្នាំ២០០៩

# សេចក្ដីបញ្ចប់

សម្រាប់ហេតុផល ដែលបានកត់សម្គាល់រួចហើយ ក៏មិនអាចទៅរួចក្នុងការដឹងអំពីទំហំពិតនៃការធ្វើទារុណកម្ម និងការធ្វើបាបអ្នកជាប់ពន្ធនាគារនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែនេះ ច្បាស់ណាស់ថាអ្នកជាប់ពន្ធនាគារជាច្រើន បន្តត្រូវបានរងនូវការធ្វើបាបទាំងផ្លូវកាយ និងផ្លូវចិត្តនៅអំឡុងពេលនៃការឃុំខ្លួនរបស់អាជ្ញាធររដ្ឋ ហើយអ្នកទាំងនោះមានលទ្ធភាពតិចតួចក្នុងការទទួលបានយន្តការបណ្ដឹងដ៏មានប្រសិទ្ធិភាព និងការផ្ដល់សំណង ហើយអ្នកដែលទទួលខុសត្រូវលើបញ្ហានេះ កម្រនឹងត្រូវបានផ្ដន្ទាទោសតាមច្បាប់ណាស់។

នៅខណៈដែលឃើញច្បាស់ អំពីការវិវឌ្ឍគួរឲ្យកត់សម្គាល់ឆ្ពោះទៅការកាត់បន្ថយកម្រិត នៃការធ្វើទារុណកម្មនៅកម្ពុជាអស់ជាច្រើនទសវត្សន៍ចាប់តាំងពីរបបខ្មែរក្រហមមក ការវិវឌ្ឍនេះ ត្រូវបានអាក់ខានទាំងស្រុងនាពេលថ្មីៗនេះ ដោយមិនមានការរីកចំរើនដ៏ល្អ និងច្បាស់លាស់នោះឡើយ ចាប់តាំងពីពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម (OPCAT) ត្រូវបានផ្ដល់សច្ចានុម័តនៅឆ្នាំ២០០៧។

គួរឲ្យសោកស្ដាយណាស់ អស់ពេលជិត ២២ឆ្នាំ បន្ទាប់ពីកម្ពុជាបានផ្ដល់សច្ចានុម័ត លើអនុញ្ញាទប់ស្កាត់ទារុណកម្មរបស់អង្គការសហប្រជាជាតិ និងជាង ៧ឆ្នាំចាប់តាំងពីការផ្ដល់សច្ចានុម័តលើពិធីសារបន្ថែមលើអនុសញ្ញាទប់ស្កាត់ទារុណកម្ម (OPCAT) ប្រព័ន្ធច្បាប់ និងតុលាការកម្ពុជា នៅតែមិនអាច ឬមិនមានឆន្ទៈក្នុងការបង្ការ និងដាក់ទណ្ឌកម្មឲ្យមានប្រសិទ្ធិភាព លើសកម្មភាពទារុណកម្មនោះទេ។

ទោះបីជាអាជ្ញាធរកម្ពុជា បានថ្កោលទោសការធ្វើទារុណកម្មដោយបើកចំហ និងញឹកញាប់ក៏ដោយ ក៏ការបន្តកើតឡើងនៃសកម្មភាពនេះ នៅតែត្រូវបានបដិសេធ ឬ ព្រងើយកន្តើយ។ នៅខណៈនេះ អ្នកប្រព្រឹត្តអំពើល្មើស មិនត្រូវបានទទួលទណ្ឌកម្ម ហើយអ្នកដែលរងគ្រោះ មិនទាន់ទទួលបានការការពារ និងសំណងនៅឡើយទេ។

ដរាបណាតុលាការកម្ពុជា បន្តទទួលយកសាក្ខីកម្ម ឬការសារភាព ដែលទទួលបានក្រោមការបង្ខិតបង្ខំ និងនៅខណៈពេលដែលអ្នកដែលបញ្ជា សម្របសម្រួល ឬប្រព្រឹត្តអំពើទារុណកម្មទទួលបាននិទណ្ឌភាព នោះការប្ដេជ្ញាចិត្តពិតប្រាកដរបស់កម្ពុជា ក្នុងការហាមឃាត់យ៉ាងដាច់ខាតលើការធ្វើទារុណកម្ម និងការធ្វើបាប និងនៅតែមិនអាចសម្រេចបាន។

នៅខណៈដែលបុរស ស្ត្រី និងកុមារ បន្តទទួលរងការវាយដំគម្រាមកំហែង និងធ្វើឲ្យពិការនៅពេលមានការឃុំខ្លួនដោយអាជ្ញាធររដ្ឋ អាជ្ញាធរកម្ពុជា ត្រូវតែទទួលស្គាល់ថា អ្នកទាំងនោះត្រូវទទួលខុសត្រូវដោយផ្ទាល់ និងត្រូវតែចាត់វិធានការណ៍ជាបន្ទាន់ក្នុងការផ្ដល់យន្តការការពារដ៏ខ្លាំងមួយ និងដែលប្រកបដោយការទទួលខុសត្រូវ។



បន្ទប់ឃុំឃាំងសម្រាប់អ្នកទោសជាបុរសរបស់ពន្ធនាគារកម្ពុជា ឆ្នាំ២០១៣

**យោបល់មួយចំនួន៖**

អង្គការ លីកាដូ សូមផ្តល់នូវយោបល់ជាអាទិភាពចំនួន ដប់ពីរចំនុច ជូនដល់រាជរដ្ឋាភិបាលកម្ពុជា៖

►►► រៀបចំ និងអនុម័តច្បាប់ស្តីពីការទប់ស្កាត់ការធ្វើទារុណកម្មជាក់លាក់ ដោយធ្វើការបញ្ចូលក្នុងច្បាប់ជាតិ នូវនិយមន័យនៃការធ្វើទារុណកម្ម ដែលមាននៅក្នុងមាត្រា ១ នៃអនុសញ្ញាទប់ស្កាត់ទារុណកម្មរបស់អង្គការសហប្រជាជាតិ និងកំណត់អំពើនៃការធ្វើទារុណកម្មថាជា បទល្មើសព្រហ្មទណ្ឌ និងដាក់ទោសដោយទណ្ឌកម្មសមរម្យមួយចំនួន។

►►► បង្កើតយន្តការបង្ការថ្នាក់ជាតិឯករាជ្យពិតប្រាកដមួយ ដែលមានសមាសភាពមកពីអ្នកជំនាញឯករាជ្យ ដែលមានសមត្ថភាពគ្រប់គ្រាន់ ហើយដែលមិនស្ថិតក្រោមឥទ្ធិពលរបស់រាជរដ្ឋាភិបាល និងមានលទ្ធភាពធ្វើការងារដោយឯករាជ្យ ហើយនិងមានស្វ័យភាពថវិកាផងដែរ។

►►► ធានាថាគ្រប់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីពន្ធនាគារទាំងអស់យល់នូវអ្វី ដែលជាការធ្វើទារុណកម្ម និងការធ្វើបាប ហើយនឹងការហាមឃាត់ដាច់ខាត។

►►► ធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានា ថាអ្នកជាប់ពន្ធនាគារទទួលបានសិទ្ធិទំនាក់ទំនងជាមួយមេធាវី បងប្អូន ឬ អ្នកដទៃ គ្រប់ពេលវេលា នៅអំឡុងពេលឃុំខ្លួនដោយនគរបាល សិទ្ធិទទួលបានការពារពីមេធាវីអំឡុងពេលសាកសួរ និងសិទ្ធិទទួលបានការពិនិត្យសុខភាពដែលឯករាជ្យ ប្រសិនបើមានការស្នើសុំ។

►►► ចាត់វិធានការណ៍ជាបន្ទាន់ ដើម្បីធា នា ថាគ្រប់អ្នកជាប់ពន្ធនាគារទាំងអស់ ត្រូវបានប្រាប់អំពីសិទ្ធិរបស់អ្នកទាំងនោះ បន្ទាប់ពីមានការចាប់ខ្លួន រួមទាំងសិទ្ធិក្នុងការមិនឆ្លើយសំនួររបស់នគរបាល សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម និងសិទ្ធិក្នុងការដាក់ពាក្យបណ្តឹង។

►►►ហាមឃាត់ការប្រើប្រា ស់ ការសារភាពជាភស្តុតាងដែលអាចទទួលយកបាននៅក្នុងតុលាការលុះត្រាតែការសារភាពនោះត្រូវបានធ្វើដោយមានវត្តមាន និងបន្ទាប់ពីប្រឹក្សាពីមេធាវីការពារជនជាប់ចោទ។

►►► ចាត់វិធានការណ៍បន្ទាប់ ដើម្បីធ្វើឲ្យប្រសើរនូវល័ក្ខខ័ណ្ឌនៃការឃុំខ្លួននៅក្នុងពន្ធនាគារ និងកាត់បន្ថយភាពចង្អៀតណែន។ ជំហានដំបូង បង្កើន កា រប្រើប្រាស់វិធានការណ៍ដែលមិនមានការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ និងការប្រើប្រាស់ទោសដែលមិនចាំបាច់ឃុំខ្លួន។

►►► ធានាថាមានតែមន្ត្រីពន្ធនាគារប៉ុណ្ណោះ ដែលមានសិទ្ធិក្នុងការអនុវត្តវិន័យលើអ្នកជាប់ពន្ធនាគារ។ គ្រប់ករណីនៃការរំលោភបំពាន និងការធ្វើបាប ដែលត្រូវបានប្រព្រឹត្តដោយអ្នកជាប់ពន្ធនាគារផ្សេងទៀត ត្រូវតែមានការស៊ើបអង្កេត និងដាក់ទោស ហើយប្រសិនបើមន្ត្រីពន្ធនាគារណាត្រូវបានរកឃើញថាមិនអើពើ ឬ បណ្តោយឲ្យមានអំពើនេះ ត្រូវតែទទួលខុសត្រូវមុខច្បាប់។

►►► បង្កើតស្ថាប័នត្រួតពិនិត្យស៊ីវិលឯករាជ្យមួយ ដែលមានសមត្ថភាពក្នុងការទទួល និងដោះស្រាយបណ្តឹងដោយផ្ទាល់ទៅលើនគរបាល និងមន្ត្រីអនុវត្តច្បាប់ដទៃទៀត ឲ្យបានសមស្រប។

►►► ធានាថាមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីផ្សេងទៀតនៃអាជ្ញាធររដ្ឋ ដែលត្រូវបានចោទថាបានធ្វើទារុណកម្ម និងការធ្វើបាបដទៃទៀត ត្រូវបានស៊ើបអង្កេតដោយឯករាជ្យ ទាន់ពេលវេលា និងពេញលេញ ហើយប្រសិនបើសមរម្យ ត្រូវតែទទួលទោសទៅតាមច្បាប់។

►►► បង្កើតកម្មវិធីរបស់រដ្ឋការពារជនរងគ្រោះ និងសាក្សី ដែលធានាបាននូវការរក្សាការសម្ងាត់ និងការការពារអ្នកដែលមករាយការណ៍ ឬ ប្តឹងអំពីអំពើទារុណកម្ម ហើយធានាថាជនរងគ្រោះ ត្រូវបានផ្តល់ការស្តារសម្បាទាឡើងវិញ រួមទាំងការផ្តល់សំណងសមរម្យ និងការស្តារសម្បាទាពេញលេញតាមដែលអាចធ្វើទៅបាន។

►►► អនុញ្ញាតឲ្យមានកើនឡើង នៃការអង្កេតមើលគ្រប់កន្លែងនៃការឃុំខ្លួន ដោយអ្នកអង្កេតការណ៍ឯករាជ្យ និងបញ្ចប់ការរឹតត្បឹត ដែលមិនត្រឹមត្រូវមកលើការចូលក្នុងពន្ធនាគាររបស់អង្គការ លីកាដូ។ អង្គការ លីកាដូ និងអ្នកអង្កេតដទៃទៀត ត្រូ វតែអាចធ្វើការសម្ភាសដោយសម្ងាត់ជាមួយគ្រប់អ្នកជាប់ពន្ធនាគារទាំងអស់។

www.licadho-cambodia.org